# ការសម្ភាសន៍របស់អ្នកមីង ទិត្យ ថាវី

កៈ អ្នកសម្ភាសន៍គេមាន រត្ន ពិសី ខៈ អ្នកដែរគេត្រូវសម្ភាសន៍មាន ទិត្យ ថាវី

## <u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់អ្នកមីង ទិត្យ ថាវី</u>

ការសម្ភាសន៍ជីវប្រវត្តិរបស់អ្នកមីង ទិត្យ ថាវីដែលអ្នកមីងមានការលំបាកហើយជួបនៅឧបសគ្គជាច្រើនតែគាត់ជាមនុស្សដែលខិតខំព្យាយាមតស៊ូហើយគាត់ចេះធ្វើការរកស៊ីតាំងពីក្មេងមកគាត់ជាមនុស្សស្លូតបូតចេះរាប់អានញ្ញាតិមិត្តជិតខាងចេះរាប់អានអ្នកដ៏ទៃគាត់មានបំណងប្រាថ្នាតាំងពីតូចមកគឺចង់រកស៊ី។ហើយគាត់បានខិតខំចិញ្ចឹមចៅឲ្យក្លាយជាមនុស្សល្អហើយគាត់បានប្រាប់ចៅរបស់គាត់ខំរៀនសូត្រហើយកុំដើរតាមផ្លូវចាស់របស់គាត់ហើយគាត់ជាមនុស្សដែរមានការលំបាកតាំងពីក្មេងហើយគាត់បានតស៊ូពីបាតដៃទទេ។ធ្វើឡើងនៅភូមិបឹងសាឡាង សង្កាត់ឬស្សីកែវ ខ័ណ្ឌឬស្សីកែវ ភ្នំពេញធ្វើឡើងនៅថ្ងៃទី០៨ ខែ ០៥ ឆ្នាំ២០១៨។

កៈ ជាដំបូងខ្ញុំសូមជំរាប់សួរអ្នកមីងខ្ញុំបាទមានឈ្មោះថា រត្ន ពិសី ហើយសូមអនុញ្ញាតអ្នកមីងធ្វើការសម្ភាសន៍ជីវប្រវត្តិរបស់អ្នកមីងហើយខ្ញុំធ្វើឡើងដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថា សាកលវិទ្យាល័យ BYU ហើយដែលមានទីតាំងនៅសហរដ្ឋអាមេរិចអញ្ចឹងអ្នកមីង។ហើយដើម្បីថែរក្សាជីវប្រវត្តិរបស់អ្នកមីងហើយដើម្បីថែរក្សាជីវប្រវត្តិជីដូនជីតារបស់អ្នកមីងទុកឲ្យកូនចៅជំនាន់របស់អ្នកមីងថាអ្នកមីងមានការលំបាកយ៉ាងណាដែលពេលដែលការរកស៊ីចិញ្ចឹមពួកគាត់ហើយដើម្បីឲ្យគាត់បានធំធាត់អញ្ចឹងហើយអ្នកមីង។

ខៈ ចាំ! ហើយរាល់ថ្ងៃនិងចិញ្ចឹមចៅរាល់ថ្ងៃ។

កៈ បាទ!

ខៈ ហើយចៅកំព្រារងាព្រោះអីម៉ែឪវាលែងគ្នាអញ្ចឹងណាស់។

កៈ បាទ! ហើយអញ្ចឹងអត់ទោសអ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខៈ ខ្ញុំមានឈ្មោះថា ទិត្យ ថាវី។

កៈ បាទ! អ្នកមីងមានឈ្មោះថា ទិត្យ ថាវី។

ខៈ ចាំ!

កៈ បាទ! ហើយអញ្ចឹងអ្នកមីងខ្ញុំធ្វើឡើងនិងនៅថ្ងៃទី០៨ ខែ ០៥ ឆ្នាំ ២០១៨ ។

ខៈ ចា៎! ឆ្នាំ២០១៨។

កៈ បាទ! ហើយអញ្ចឹងអត់ទោសអ្នកមីងនៅនិងគេហៅភូមិអីដែរអ្នកមីង?

ខៈ ខ្ញុំនៅភូមិបឹងសាឡាង សង្កាត់ ឬស្សីកែវ ខណ្ឌ ឬស្សីកែវ រាជធានីភ្នំពេញ។

កៈ បាទ! ភូមិបឹងសាឡាង សង្កាត់
ឬស្សីកែវ។ហើយអញ្ចឹងអ្នកមីងមានអាយុប៉ុន្មានហើយអ្នកមីង?

ខៈ ខ្ញុំមានអាយុ ៥៣។

កៈ បាទ! អ្នកមីងមានអាយុ
៥៣អ្នកមីង។ហើយអញ្ចឹងអ្នកមីងបើឆ្នាំខ្មែរយើងវិញនិងឆ្នាំអីដែរអ្នកមីង?

ខៈ ខ្ញុំឆ្នាំ មមែ។

កៈ បាទ! អ្នកមីងឆ្នាំ មមែ
។ហើយអញ្ចឹងអ្នកមីងមានចាំថាអ្នកមីងកើតនៅថ្ងៃទីឆ្នាំណាទេអ្នកមីង?

ខៈ ខ្ញុំកើតនៅឆ្នាំ១៩៧៣។

កៈ បាទ! អ្នកមីងកើតនៅឆ្នាំ១៩៧៣អ្នកមីង។

ខៈ ចា៎! អត់ទេឆ្នាំ១៩៧០។

កៈ បាទ! អ្នកមីងកើតនៅឆ្នាំ១៩៧០។

ខៈ ចា៎!

កៈ បាទ!

ខៈ ដូចខែយើងអត់ចាំហើយយើងចាំតែឆ្នាំណាស់។

កៈ បាទ!

ខៈ ព្រោះអីខ្ញុំអត់ចាំទេព្រោះអីវាកន្លងផុតសតវត្សទី៥៣ហើយណាស់។

កៈ បាទ! សតវត្ស៥៣ហើយអ្នកមីង។

ខ៖ ចាំ! សតវត្សុ៥៣ហើយអត់ចាំទេ។

ក៖ បាទ! ហើយអញ្ចឹងអត់ចាំទេអ្នកមីង។

ខ៖ ចាំ! អត់សូវចាំទេ។

ក៖ បាទ! ហើយអញ្ចឹងអ្នកមីងមានឈ្មោះហៅខាងក្រៅទេ?

ខ៖ ខ្ញុំមានឈ្មោះខាងក្រៅមានឈ្មោះ ហាន។

ក៖ បាទ! ហើយអ្នកមីងមានឈ្មោះ ហានអ្នកមីងណោះ?

ខ៖ ចាំ! គេហៅខ្ញុំមីងហានៗ។

ក៖ បាទ! ហើយអញ្ចឹងហៅមីងហានទៅ។

ខ៖ ចាំ!

ក៖ បាទ!

ខ៖ ហើយអ្នកខ្លះគេហៅម្ដាយអាមី។

ក៖ បាទ! គេហៅម្ដាយអាមី។

ខ៖ ចាំ!
គេហៅម្ដាយអាមីនិងហើយគេច្រើនហៅតាមឈ្មោះម្ដាយអាមីអញ្ចឹងណាស់តាមស្រុកនិង។

ក៖ បាទ!

ខ៖ ហើយបើនៅតាមស្រុកស្រែអញ្ចឹង។

ក៖ បាទ!

ខ៖ យាយហៅថាមីហានអើយមកពីកាលពេលយើងទៅបុណ្យទានអញ្ចឹងណាស់។

ក៖ បាទ! បុណ្យទាន។

ខ៖ ចាំ!
ហើយខ្ញុំថាចាំអ៊ុំខ្ញុំទើបមកមិញនិង។ហើយអ៊ុំមកអង្គុយលេងសិនទៅមានតែប៉ុណ្ណឹង។

កៈ
បាទ!ហើយអញ្ចឹងអ្នកមីងមានចាំថាអ្នកមីងស្រុកកំណើតអ្នកមីងថានៅភូមិឃុំណាទេអ្នកមីង?

ខៈ នៅភូមិគល់ដំបែក ឃុំ៣ទីរូមខេត្តស្វាយរៀង។

កៈ អរទីរូមខេត្តស្វាយរៀងអរអ្នកមីងអ្នកស្វាយរៀងអ្នកមីង?

ខៈ ចា៎!ខ្ញុំជាអ្នកស្វាយរៀងតា។

កៈ បាទ!ចឹងតើអ្នកមីងមានបងប្អូនប៉ុន្មាននាក់ដែលអ្នកមីងបងប្អូនបង្កើតណាស់អ្នកមីង?

ខៈ បងប្អូនបង្កើតនឹងនិយាយទាំងអ្នកស្លាប់នឹងអ្នករស់មែន។

កៈ បាទ!អ្នកមីង?

ខៈ សរុបទាំងអស់១១នាក់ស្លាប់ជំនាន់អាពត២នាក់ អាវ៉ាត អាវ៉ា
នឹងស្លាប់មួយថ្ងៃមួយគាត់មានអាយុ៨ឆ្នាំ៩ឆ្នាំ។

កៈ អរបាទ!ចឹងមួយ៨ឆ្នាំមួយទៀត៩ឆ្នាំបងវ៉ា៨ឆ្នាំមួយទៀត៩ឆ្នាំវ៉ាត?

ខៈ ចា៎!ដល់ពេលស្លាប់ទៅម៉ែខ្ញុំគាត់មានកូនខ្ចីទៀតក៏យកឈ្មោះនឹងដាក់វិញទៅ។

កៈ បាទ!យកឈ្មោះនឹងដាក់វិញទៀត?

ខៈ ចា៎!អាវ៉ាត អាវ៉ា។

កៈ បាទ!ចឹងអ្នកមីងជាកូនទីប៉ុន្មានដែលអ្នកមីង?

ខៈ ខ្ញុំជាកូនទី២។

កៈ
អរចឹង!អ្នកមីងជាកូនទី២ចឹងអ្នកមីងបងប្អូនអ្នកមីងនឹងតើមានប្រុសប៉ុន្មានស្រីប៉ុន្មានដែលអ្នកមីង?

ខៈ ស្រី២នាក់បងគេនឹងគាត់ស្រីដែលបន្តបមកទី២ខ្ញុំនឹង។

កៈ បាទ!ស្រី២តើប្រុសប៉ុន្មានដែលអ្នកមីង?

ខៈ ប្រុស៩បើស្លាប់២នាក់វានៅសល់៧។

ក៖ ចឹងប្រុសនៅសល់៧នាក់?

ខ៖ ចាំ!និយាយទៅនៅសល់៧នឹង។

ក៖ បាទ!ចឹងអ្នកដែលស្លាប់នឹងប្រុសទាំង២នាក់អ្នកមីង?

ខ៖ ប្រុសទាំង២នាក់នឹងល្អណាស់តែវាចេញកន្ទីលកាលជំនាន់អាពតនឹងណាស់។

ក៖ បាទ!

ខ៖ ម៉ែខ្ញុំគាត់មិនដឹងធ្វើគាត់មិនដឹងធ្វើមិចទេ។

ក៖ បាទ!ចឹងអ្នកមីងតើបងស្រីអ្នកមីងនឹងតើគាត់មានឈ្មោះអ្វីដែលអ្នកមីង?

ខ៖ ទិត្យ សាប៊ី។

ក៖ បាទ!ទិត្យ ថាប៊ីបាទចឹងបន្ទាប់ពីអ្នកមីងណាស់?

ខ៖ ទិត្យ សារ៉ែន ទិត្យ ចាន់ថន ទិត្យ សេនា ទិត្យ ចាន់រឿន ទិត្យ វ៉ាត ទិត្យ ស៊ីណា ហើយទេ
។

ក៖ នៅទេអ្នកមីង?

ខ៖ ចាំ!ហើយបានទិត្យ វ៉ាត ទិត្យ វ៉ា ។

ក៖ បាទ!ទិត្យ វ៉ាត ទិត្យ វ៉ា ?

ខ៖ ចាំ!ហើយបានទិត្យ លា នឹងហើយពៅគេ។

ក៖ បាទ!

ខ៖ អានឹងវាអត់ដូរទេបើអា២នាក់នឹងវាទី៣ ទី៤ ទី៥ នឹងពៅចឹងណាស់។

ក៖ បាទ!

ខ៖ អា២នាក់នឹងវាកើតមកដាក់ឈ្មោះ អា វ៉ាត អា វ៉ា។

ក៖ បាទ!

ខ៖ ចាំ!ហើយឥឡូវវាជាងសំណងទាំង២នាក់។

ក៖ អរចឹងតើគាត់ធ្វើនៅណាដែលអ្នកមីង?

ខ៖ គាត់ដើរធ្វើតែឥឡូវ។

ក៖ គាត់ម៉ៅការគេមែនអ្នកមីង?

ខ៖ គាត់ម៉ៅការប៉ុនគាត់នៅខាងខូតដូរ។

ក៖ អរម៉ៅការខូនដូរគេមែនអ្នកមីង?

ខ៖ គាត់ម៉ៅការគេនៅម្តុំផ្សារដើមគរជិតផ្សារដើមគរ។

ក៖ អរចឹងតើគាត់មានគ្រួសារហើយអស់អ្នកមីង?

ខ៖ កូន២នាក់ហើយ។

ក៖ អរកូន២ហើយអ្នកមីង?

ខ៖
ចាំ!អានឹងបន្ទាប់ពៅនឹងវាគ្រាន់បើជាងគេនឹងដូចថាវារៀងថាំហើយបងប្អូនវាអាចជួយបាន វាអាសាមកលេងណាស់។

ក៖ បាទ!ចឹងគាត់ជួយអ្នកមីងដែលតាអ្នកមីង?

ខ៖
នឹងហើយវាជួយព្រោះអានឹងពេលវាពេញកំលោះដូចថាវាទៅធ្វើការសំណាងអីចឹងដូចថាវាអត់មានលុយទៅស្រុកអីចឹងណាស់វាមកបងចឹងទៅបងនឹងបេះពីមាត់ពីកនឹងយកអោយប្អូនមកស្រុក។

ក៖ អរចឹងគាត់ដឹងគុណណាស់?

ខ៖ ចាំ!គាត់ដឹងគុណណាស់គាត់ដឹងគុណជាងគេណាស់។

ក៖ បាទ!

ខ៖
អាមួយនឹងខ្ញុំមិននិយាយទេប៉ុន្តែក្រៅពីនឹងមានណារត់រកទេគេរត់រកអាវ៉ាអាវ៉ាតនេះមួយវាកំសត់កំរលេងល្បែង។

ក៖
បាទ!តែបងប្អូនអ្នកមីងឥឡូវតើពួកគាត់នៅណាខ្លះដែលអ្នកមីងនៅភ្នំពេញទាំងអស់គ្នាឬក៏នៅស្វាយរៀងអ្នកមីង?

ខ៖ នៅភ្នំពេញមើនៅភ្នំពេញ៤នាក់។

ក៖ បាទ!នៅភ្នំពេញ៤នាក់?

ខ៖ ចាំ!ទិត្យ យនមួយ ទិត្យ រ៉ា នឹងពីរ ទិត្យ តកនឹងបី ទិត្យ
រ៉ាតនឹងបីឈ្មោះក្រៅគេហៅថាតកហើយនឹងទិត្យ លាប្អូនប្រាំទាំងខ្ញុំនឹង។

ក៖ បាទ!ចឹង៥នាក់ទាំងអ្នកមីង?

ខ៖ ចាំ!នឹងសុទ្ធតែមានផ្ទះគេនៅភ្នំពេញអស់ហើយ។

ក៖ បាទ!អរចឹងគាត់មានផ្ទះមានអីអស់ហើយអ្នកមីង?

ខ៖ ចាំ!

ក៖ តែគាត់សុទ្ធតែមានគ្រួសារអស់ហើយអ្នកមីង?

ខ៖ ចាំ!គេមានគ្រួសារអស់ហើយ។

ក៖ មានកូនមានអីហើយ?

ខ៖ អាពីរបន្ទាប់ពៅនឹងកូន២នាក់ហើយធូរធារជាងគេអារ៉ា។

ក៖ អរចឹងបងរ៉ាគាត់ធូរធារ?

ខ៖គេម៉ៅការសំណងគេមត់ចត់ណាស់គេទិញបានឡានជិះហើយ។

ក៖ បាទ!គាត់រៀនខាងសំណងមែនអ្នកមីង?

ខ៖ អទទេដំបូងកម្មករគេតែវាយកចិត្តទុកដាក់នឹងវារៀនបានថ្នាក់ទី៤ទេណាស់។

ក៖ អរចឹងគាត់រៀបបានថ្នាក់ទី៤ទេ?

ខ៖ ចាំ!ហើយកាលនៅជាមួយខ្ញុំនឹងវាអត់ចេះទេណាស់។

ក៖ បាទ!

ខ៖
និយាយទៅបងប្អូនខ្ញុំអត់ឆ្លាតទេអត់មានអ្នកណាប្រលងជាប់ទេបានតាខ្ញុំមួយទេបានរៀនដល់ថ្នាក់ទី៥។

កៈ
បាទ!ប៉ុន្តែគាត់អត់ឆ្លាតចឹងតែពេលខ្លះគាត់ឃើញគេឃើញឯងចឹងទៅគាត់ចេះបែកគំនិតអីចឹងទៅណាស់អ្នកមីង?

ខៈ
ចា៎!បែកគំនិតដល់ពេលទៅស្រុកធ្វើបុណ្យធ្វើទាននឹងណាស់អាបងថ្លៃវានឹងទិញគោយកមកដុតដល់ហើយវាថាពូផ្សំគ្រឿងអីខ្លះចឹងណាស់សួរអ្នកដឹកគោមកណាស់គាត់ថាទឹកស៊ីអៀវខាប់២ដបប៊ីចេងស្ប្រៅស៊ូបរ៉ូតដីយកអានឹងហើយអីៗទៀតទេដល់ហើយខ្ញុំហៅអាវ៉ាមកស្តាប់គាត់ទិញអីៗយកមកប្រលាក់គ្រឿងនឹងណាស់ចូលចិត្តប្អូនវាឡើងផ្ទះវាធ្វើផ្ទះអោយម្តាយខ្ញុំអស់២ម៉ឺន។

កៈ បាទ!ធ្វើនៅស្រុកណាដែលអ្នកមីង?
ខៈ នៅស្វាយរៀងយើងនឹង។

កៈ អរនៅស្វាយរៀងនឹងអ្នកមីង?

ខៈ ចា៎!នៅភូមិ
ក្រោយដំបែកស្រុកស្វាយរៀងនឹងបណ្តាយ២១ម៉ែត្រធំហើយផ្ទះនឹងនិយាយថាទៅដេកនឹងត្រជាក់។

កៈ បាទ!ផ្ទះវីឡាមែនអ្នកមីង?

ខៈ ចា៎!គេធ្វើតា១ជាន់ទេណាស់។

កៈ បាទ!

ខៈ ខេត្តស្វាយរៀងនឹង១ជាន់បណ្តោយ២១ម៉ែត្រទទឹង៧ម៉ែត្រ។

កៈ បាទ!ធំ?

ខៈ
ចា៎!បន្ទប់៣ចាំមើបន្ទប់ដេកនឹងខាងនេះ២៥ម៉ែត្រអាក្រោយ៥ម៉ែត្រវាជិត៩ម៉ែត្រណាស់។

កៈ បាទ!

ខៈ ហើយអាក្រោយនិងបន្ទាប់ទឹកពីរ។

កៈ បាទ!បន្ទាប់ទឹកនិងពីរ។

ខ៖ ចាំ!ហើយខាងចង្រាន់នេះមួយហើយបន្ទាប់ដាក់ឥវ៉ាន់និងមួយទៀត។

ក៖ បាទ! ហើយអញ្ចឹងបន្ទាប់ទឹកបីហើយបន្ទាប់គេងបី?

ខ៖ ចាំ! បន្ទាប់គេងបួនទាំងអាផ្លូវចូលនិងមួយទៀត។

ក៖ បាទ! ហើយអញ្ចឹងផ្លូវចូលមួយទៀត។

ខ៖ ចាំ! ទាំងអស់និងបួន។

ក៖ ហើយអញ្ចឹងគាត់បានដីធំហើយអញ្ចឹងគាត់ធ្វើធំ។

ខ៖ ចាំ! គាត់បានដីធំហើយឪខ្ញុំគាត់ចែកហើយណាស់។

ក៖ បាទ!

ខ៖ ហើយដីនិងវាចូលជិតបាន១ហិតាហើយ។

ក៖ បាទ! ជិតមួយហិតាហើយអ្នកមីង។

ខ៖ ចាំ! ហើយគាត់ចែកអាប្អូនខ្ញុំអាបន្ទប់ខ្ញុំអា ខុន ។

ក៖ បាទ!

ខ៖ និងមួយប្លង់ហើយឥឡូវវាមានកូនមានចៅទៅហើយវាធ្វើឲ្យកូនវានិងម្នាក់មួយប្លង់ទៅ។

ក៖ បាទ!គាត់ចែកឲ្យកូនគាត់មួយប្លង់ទៅអ្នកមីង។

ខ៖ ចាំ! ហើយបន្ទាប់មកអាចាន់រឿនមួយប្លង់ដែរទៅ។

ក៖ បាទ!

ខ៖ ហើយបើអា
វ៉ាតនិងវាហើយដូចគេសល់លុយទៅហើយគេធ្វើផ្ទះទៅណាស់ទុកឲ្យម្ដាយខ្ញុំនៅទៅ។

ក៖ បាទ!

ខ៖
ហើយម្ដាយខ្ញុំនៅហើយប្អូនខ្ញុំវានៅដែរព្រោះវាផ្ដាប់ហើយណាស់អាមួយវាមានប្រពន្ធនៅ
ព្រៃវែង

បន្ទាប់ពៅវាធ្វរធារដែលតែគេមិនទិញផ្ទះនៅពេញទេព្រោះគេនៅព្រៃវែងគេមានផ្ទះហើយណាស់។

ក៖ បាទ!នៅជាមួយប្រពន្ធគេនឹងទៅ?

ខ៖
ចាំ!នៅជាមួយប្រពន្ធគេហើយអានោះគេសង់មួយល្វែងហើយផ្ទះវារាល់ថ្ងៃនឹងមួយល្វែងទៀតហើយវាទីទិញនៅចោមចៅមួយល្វែងទៀតពីនាក់បងប្អូនវាសង់ថ្មីម៉ង។

ក៖ សង់ថ្មីម៉ងអ្នកមីង?

ខ៖ ចាំ!និយាយទៅផ្ទះវានឹង៣ហើយ។

ក៖ បាទ!

ខ៖ ហើយផ្ទះនៅស្រុកនឹងកូនបងខ្ញុំស្រីនឹងណាស់ឈ្មោះ ការីន
និយាយមិនរួតទេអូនអើយអាសាណាស់គាត់ដាំបាយធ្វើម្ហូបអីរួតហើយត្រីមាដាណាស់ដំអោយឪខ្ញុំ៧០ឆ្នាំជាងហើយ៧៥ឆ្នាំហើយដំអោយទន់ហើយយកដាក់តាម្ហូបឆាមួយទៀតចឹងណាស់យកអោយតាគាត់ចិត្តល្អណាស់ហើយប្អូនខ្ញុំអារ៉ានឹងណាស់វាធ្វើផ្ទះហើយដីម៉ែវាចែកអោយហើយវាថាអត់អោយធ្វើផ្ទះទេផ្ទះនឹងវាអោយយាយនៅមើថៃរក្សា។

ក៖ បាត!គាត់ចិត្តបានចឹងបងប្អូនអ្នកមីងចិត្តបានល្អៗច្រើន៧នាក់ចិត្តបានទាំងអស់?

ខ៖ ចាំ!ចិត្តបានណាស់៩នាក់ទេទាំងអស់១១ស្លាប់អស់២នាក់នៅ៩។

ក៖ បាទ!នៅសល់៩នាក់?

ខ៖
ចាំ!ចិត្តល្អណាស់ចិត្តបានទាំងអស់អាមួយនៅចេញពីម៉ែខ្ញុំទៅវាការប្រពន្ធនៅអីទេនៅផ្លូវទៅវៀតណាមណាស់។

ក៖ បាទ!

ខ៖ គេហៅថាស្វាយថ្មរវៀតណាមណាស់ចាមដូងណាស់មិនជិះតាមផ្លូវនឹង។

ក៖ បាទ!

ខ៖
ហើយដល់ពេលទៅពេលខ្ញុំរៀបចេញមកវាថាមើបងអែងចង់បានអង្គរអត់ហើយខ្ញុំសួរថាអ

ង្គរបាយរឹងឬក៏បាយទន់ហើយវាថាបាយទន់វាអត់ទាន់កិតទេដល់ស្អែកបងឯងចាំ១ថ្ងៃទៅខ្ញុំមានតាបាយរឹងហើយខ្ញុំថាបាយរឹងក៏បាយរឹងគ្មាននាក់ណាគេហូបផងនិង។

ក៖ បាទ!

ខ៖
ហើយគេថាខ្ញុំមានតែបាយរឹងបងឯងហូបអត់ហើយគេថាបងទិញអង្ករលាយទៅអញ្ចឹងណាស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំថាហោសហើយអញ្ចឹងជ្រល់តែពិបាកហើយខ្ជិលម៉ងទៅ។

ក៖ បាទ! ហើយកុំរវល់ល្អជាងអ្នកមីង។

ខ៖ ចាំ! ហើយគេឲ្យមួយបាវនិងជិតពីរខែ។

ក៖ បាទ!

ខ៖ ហើយទិញគេផ្សេងហើយខ្ញុំចង់ដឹងហើយខ្ញុំនិងទិញអង្ករនិងនៅថ្ងៃទី១៣។

ក៖ បាទ!

ខ៖ ហើយខែ០៣។

ក៖ បាទ!

ខ៖ ហើយឥឡូវនិងថ្ងៃទី១៤ហើយខែ០៤។

ក៖ បាទ!

ខ៖ ហើយថ្ងៃទី១៥ខែ០៥ទៀតវាចូលពីរខែ។

ក៖ បាទ! ហើយថ្ងៃទីប្រាំបី។

ខ៖ ចាំ! ទាល់ថ្ងៃទី១៣។

ក៖ បាទ!ទាល់ថ្ងៃទី១៣។

ខ៖ បានចូលពីរខែ។

ក៖ បាទ! បានចូលពីរខែ។

ខ៖ ហើយឥឡូវអង្ករវានៅជិត២០គីឡូ។

ក៖ បាទ!

ខ៖ ហើយដូចយើងនេះទេយើងថាមតិចទៅ។

ក៖ បាទ!

ខ៖
ហើយប្រលឹមឡើងអញ្ចឹងទៅខ្ញុំទៅផ្សារទិញម្ហូបហើយខ្ញុំបានមកដល់ម៉ោង៩ទៅ១០អញ្ចឹង
ខ្ញុំធ្វើម្ហូបរួចស្រេចអញ្ចឹងណាស់។

ក៖ បាទ!

ខ៖
ហើយដាំបាយមួយកំប៉ុងពីរកំប៉ុងកន្លះខ្លះបីកំប៉ុងហើយកាលណាខ្ញុំឃ្លានហើយអញ្ចឹងណា
ស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំឃ្លានខ្លាំងអញ្ចឹងដាក់បីកំប៉ុងណាស់។

ក៖ បាទ!

ខ៖ ហើយមានអីវាហូបបានតិចៗដែរនិង។

ក៖ បាទ!

ខ៖ ហើយយើងកុំឲ្យអត់ហ្គាសច្រើន។

ក៖ បាទ!

ខ៖ ហើយពេលខ្លះដូរហ្គាសបីកំប៉ុងនិងបានមួយអាទិត្យអីអញ្ចឹងទៅ។

ក៖ បាទ!

ខ៖ ចាំ!
ហើយរាល់ថ្ងៃនិងយើងសន្សំសំចៃខ្ញុំរាល់ថ្ងៃនិងខ្ញុំបានកូនស្រីមួយដែរមានឈ្មោះមីដានិង
ហើយខ្ញុំមានតែកូនបីនាក់និងទេ។

កះ បាទ!

ខះ ហើយម៉ែមីតូចមិញនិងណាស់។

កះ បាទ! ៗ

ខះ
ហើយមកខ្ញុំហើយខ្ញុំសាងអំពើល្អដែរខ្ញុំហើយដូចម្ដេចហើយយើងជំពាក់កម្មគេពីជាតិមុនអីម្ដេចទេអូនអើយ។

កះ បាទ!

ខះ ហើយដូចបានគ្នាហើយអាណុងវារត់ចោលទៅ។

កះ បាទ!

ខះ
ហើយអាណុងវាមកដែរតែវាអត់យកហើយម្ដាយមីងគេថាយើងនិងអត់កំណើតអញ្ចឹងណាស់ហើយម្ដាយមីងគេអ្នកមានណាស់។
កះ បាទ! គេមើលងាយយើងអ្នកមីង។

ខះ គេមើលងាយយើងនិងហើយតែពួកវានិងស្រឡាញ់គ្នានិងវាពាក់ខ្សែកនិងមួយខ្សែនិង។

កះ បាទ!គាត់ពាក់ខ្សែកនិងមួយខ្សែអ្នកមីង។

ខះ ចាំ!
ខ្សែកនិងប្រាក់ទិនហើយវាធ្វើការទៅបានមួយខែ៥០ទៅ៦០ណាស់ដែរប្រាក់ខែវានិងណាស់។

កះ បាទ!

ខះ ហើយវាទើបតែអាយុ១៥ទេ។

កះ ហើយអញ្ចឹងគាត់ធ្វើការអីគេដែរអ្នកមីង?

ខះ ចាំ! ពីមុននិងវាធ្វើការរោងចក្រ។

កះ បាទ! គាត់ធ្វើការរោងចក្រអ្នកមីង។

ខ៖ ចាំ! ហើយដល់ពេលទៅហើយដោះខ្សែកនិងចេញទៅខ្ញុំទិញប្រាក់ទិនបីជីប្រាំហ៊ុនយកកូនពាក់ហើយជញ្ជៀនប្រាំហ៊ុនទៀតធ្វើឲ្យកូនពាក់ណាស់។

ក៖ បាទ!

ខ៖ ហើយដូចថាវាតាមគ្នាទៅណាស់។

ក៖ បាទ!

ខ៖ ហើយវាលក់ចាយទៅណាស់។

ក៖ បាទ!

ខ៖ ហើយវាគ្នាហើយខ្ញុំខឹងហើយខ្ញុំថាកូនកុំទៅណាពេលយប់ប្រលប់និងហើយអាណុងវាចេះតែតេហៅអញ្ជឹងណាស់។

ក៖ បាទ! ហើយគាត់តេហៅជិះដើរលេងអ្នកមីង។

ខ៖ ហើយវាថាទៅដើរលេងមួយភ្លេតៗអញ្ជឹងហើយយើងដឹងថា១៨អញ្ជឹងណាស់។

ក៖ បាទ!

ខ៖ ហើយវាបានគ្នាទៅហើយគេថាស្រែមិនស្រែក្រុងមិនក្រុងអញ្ជឹងណាស់។

ក៖ បាទ!

ខ៖ ហើយចំពោះម៉ែវាគេពេញចិត្តវានាំទៅឲ្យម៉ែវាមើលអញ្ជឹងណាស់។

ក៖ បាទ!

ខ៖ ហើយគេប្រើកូនយើងលាងចាន់លាងឆ្នាំងបោកខោអាវឲ្យសម្អាតបាតអីហើយអញ្ជឹងទៅ។

ក៖ បាទ!

ខ៖ ហើយបោសសម្បុកពេញពាងអញ្ជឹងណាស់។

ក៖ បាទ!

ខ៖ ហើយគាត់ថាគាត់ពេញចិត្ត។

ក៖ បាទ! គេពេញចិត្ត។

ខ៖ ហើយគេថាមីងខាងម៉ែគេនិងគេអ្នកមានហើយគេមានផ្ទះហើយគេមានឡានអីអញ្ចឹងណាស់។

ក៖ បាទ!

ខ៖ ហើយគេដូចថាគេរីសគុណយើងអីអញ្ចឹងណាស់។

ក៖ បាទ! ហើយគេមានខ្សែអ្នកមានអញ្ចឹងអ្នកមីង?

ខ៖ មិនមែនទេហើយគេថាមានតែមីងវានិងមួយទេ។

ក៖ បាទ!

ខ៖ ហើយគេតាមជីកគោះអីអញ្ចឹងណាស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំថាកូនអើយកុំតូចចិត្តនិងវាសនាហើយកុំតវ៉ានិងព្រហ្មលិខិត។

ក៖ បាទ!

ខ៖ បើគូរព្រេងយើងវាមិនព្រាត់ទេហើយនេះហើយមិនមែនគូរព្រេងទេនេះហើយជាគូរកម្ម។

ក៖ បាទ!

ខ៖ ហើយខ្ញុំថាចែកផ្លូវគ្នាល្អជាង។

ក៖ បាទ!

ខ៖ ហើយឥឡូវវាមានសំណាងវាបានទៅបារាំងនិងទៅផង។

ក៖ បាទ!

ខ៖ ហើយបានខ្ញុំដេកស៊ីនិងរហូតនិងទៅណាស់។

កៈ បាទ! ហើយរាល់ថ្ងៃនិងគាត់បានប្តីបារាំងអ្នកមីង។

ខៈ ចាំ!

កៈ ហើយប្តីបារាំងគាត់នៅបារាំងឬមកនៅខ្មែរអ្នកមីង?

ខៈ ហើយនៅបារាំងនិងវាទៅមក។

កៈ បាទ! គាត់ទៅមកៗអ្នកមីង?

ខៈ ចាំ! ហើយវាមកលេងកូនវានិង។ហើយដូចកូនខ្ញុំថាមិនឲ្យនៅនិងក្លាយវាធ្វើការ។

កៈ បាទ!

ខៈ ហើយវាក្លាយយើងទៅធ្វើការណាផ្សេងទៀតអញ្ចឹងណាស់។

កៈ បាទ!

ខៈ
ហើយវាមិនថាយើងមិនស្មោះត្រង់អញ្ចឹងណាស់ហើយអញ្ចឹងវាឲ្យទៅជាមួយវានិងបានកន្លះខែហើយ។

កៈ បាទ!

ខៈ ហើយទើបតែមកថ្ងៃនិងដែរនិង។

កៈ បាទ! ហើយអញ្ចឹងគាត់ចុះពីលានមកអ្នកមីងណោះ។

ខៈ ចាំ! ហើយអាវិននឹងទៅយក។

កៈ បាទ!

ខៈ គេធ្វើការជាមួយគ្នានិងណាស់។

កៈ បាទ!

ខៈ ធ្វើការជាមួយគ្នាជាមួយអាបារាំងកូនខ្ញុំនិងណា។

កៈ បាទ!

ខៈ ចាំ!

កៈ ហើយអញ្ជឹងអ្នកមីងមានចាំសាច់រឿងជាមួយ។

ខៈ កាលពីជំនាន់អាពតមែន។

កៈ បាទ! នឹងហើយអ្នកមីងហើយនិងជាមួយបងប្អូនរបស់អ្ន
កមីងកាលដែលអ្នកមីងនៅពីក្មេងណាស់អ្នកមីង?

ខៈ ចា៎! ខ្ញុំអត់ដឹងថាធ្វើអីជាមួយគ្នាផងនិង?

កៈ បាទ! ដូចថាមានធ្លាប់ទៅដកប្រលឹតនិងជាមួយគ្នាអញ្ជឹងអ្នកមីងមានចាំទេអ្នកមីង?

ខៈ អរ! ខ្ញុំចាំតា។

កៈ ដូចអ្នកមីងធ្លាប់ទៅណាជាមួយគ្នាអញ្ជឹងអ្នកមីង?

ខៈ ខ្ញុំចាំតាអត់ដកប្រលឹតទេអរកាល៧៩និងអត់ទេ៨០។

កៈ បាទ! ៨០សិបអ្នកមីង។

ខៈ ចា៎! ៨៣ទៅ៨៤។

កៈ បាទ!

ខៈ ហើយ៧៩បានអាពត។ហើយ៨៣ទៅ៨៤គេមានសាលារៀនហើយអូន។

កៈ បាទ! ហើយនិងដាច់អាពតហើយអ្នកមីង?

ខៈ ចា៎! ឪខ្ញុំនិងខ្ញុំចង់រៀនណាស់ហើយខ្ញុំថាឃើញគេទៅរៀនអញ្ជឹងអង្គុយសង្កឹក។

កៈ បាទ!

ខៈ ព្រោះអីយើងអ្នកក្រហើយឪខ្ញុំកូនច្រើនឪពុកខ្ញុំកូនដល់ទៅ៩នាក់។

កៈ បាទ!

ខៈ ហើយគាត់មួយឆ្នាំមួយហើយពីរបីឆ្នាំមួយហើយអញ្ជឹងណាស់។

កៈ បាទ!ៗ

ខៈ ហើយដើរទៅលួចត្រពាំងនិង។

កៈ បាទ!

ខ៖
អូនហើយខ្ញុំណាស់ហើយម្ដាយខ្ញុំដំបូងនិងហើយគាត់ធ្វើនំពងម្សមហើយគាត់ពឹងធ្វើណាស់ហើយនិងបាញច្រណឹក
ហើយគាត់ទៅលក់ហើយដូចថាយើងនិងទៅតាមគាត់លក់ហើយយើងយួរអាក្រតូលលាងចាន់និង។

ក៖ បាទ!

ខ៖ ហើយជំនាន់និងមានដឹងថាដើរទៅដងទឹកណា។

ក៖ បាទ!

ខ៖ ហើយខ្ញុំនិងដងទឹកលាងចាន់និងទៅតាមម្ដាយខ្ញុំនិងទៅ។

ក៖ បាទ!
ហើយអញ្ជឹងអ្នកមីងបានដើរទៅលក់ជាមួយគាត់ទៅ។ហើយអញ្ជឹងអ្នកមីងមានចាំថាអ្នកមីងទៅលក់ទៅណាទេអ្នកមីង?

ខ៖ ចាំ! ហើយខ្ញុំទៅលក់នៅផ្សារស្វាយរៀងនៅជាយផ្សារណាស់។

ក៖ បាទ! ហើយអញ្ជឹងអ្នកមីងទៅលក់នៅឯជាយ។

ខ៖ ចាំ! នឹងហើយខ្ញុំទៅលក់នៅឯជាយផ្សារនិងហើយពេលនិងមួយចាន់មួយកាកៗនោះ។

ក៖ បាទ! មួយចាន់មួយកាកនិងអ្នកមីង។

ខ៖ ចាំ! ហើយកាលនិងបានមួយកាកពីរកាកអឺ។

ក៖ បាទ!

ខ៖
នឹងហើយដូចថាហើយម្ដាយខ្ញុំនិងលក់អត់ស្វរដាច់ហើយគាត់វិច្ចនំអង្សមនិងទៅលក់និងទៀតទៅណាស់ហើយគាត់ឲ្យនិងយកទៅលក់និងហើយគាត់ខ្ញុំយកលក់តាំងតែម៉ោង១០។

ក៖ បាទ!

ខ៖ ហើយប្រហែលជាម៉ោង១០និងហើយលក់នៅកែងគេរត់ម៉ូតូឌុបនិងណាស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំលក់និងនៅកន្លែងគេរត់ម៉ូតូឌុបអីអញ្ចឹងណាស់។

ក៖ បាទ!

ខ៖
ហើយខ្ញុំលក់ខាងនិងហើយសាលារៀននៅខាងនេះកែងនិងបឹងគីឡូនៅផ្សារស្វាយរៀងយើងនិង។

ក៖ បាទ! នៅផ្សារស្វាយរៀងយើងនិងអ្នកមីង។

ខ៖ ចាំ! នឹងហើយដល់ពេលទៅហើយខ្ញុំដឹងថាគេបេះត្រកួន។

ក៖ គេបេះត្រកួននិងអ្នកមីង។

ខ៖ ចាំ! នឹងហើយគេបេះត្រកួនហើយគេយកទៅដូរអង្ករនិង។

ក៖ បាទ! គេយកទៅដូរអង្ករនិងអ្នកមីង។

ខ៖ ចាំ! គេយកទៅដូរអង្ករនិងអ្នកមីងឲ្យពួកវៀតណាមណាស់។

ក៖ បាទ! ដូរឲ្យពួកវៀតណាមអ្នកមីងហើយគេចូលមកទិញមែនអ្នកមីង?

ខ៖
អត់ទេគេចូលមកនៅនិងហើយ។ហើយនៅឆ្នាំ៨០ជាងនិងពួកវៀតណាមនៅតាមផ្លូវមាត់ទន្លេណាស់។

ក៖ បាទ! ហើយគេនៅតាមជាយដែនៗអ្នកមីង?

ខ៖ មានតាមជាយដែនអីហើយគេនៅទីរួមខេត្តយើងនិង។

ក៖ បាទ! គេនៅតាមទីរួមខេត្តយើងនិងអ្នកមីង។

ខ៖ ចាំ!
ហើយគេនៅតាមមាតទន្លេនិងហើយខ្ញុំនៅត្រាយខាងនេកហើយមិនឆ្លងស្ពានទៅអញ្ចឹង។

ក៖ បាទ! ៗ

ខ៖ ហើយមិនឆ្លងស្ពានទៅហើយខ្ញុំមិននៅខាងនេះ។

ក៖ បាទ!

ខ៖ ហើយគេនៅតាមមាត់ទន្លេនិងហើយដូចមានផ្ទះថ្មគេទុកចោល។

ក៖ បាទ! ដែរគេទុកចោលតាំងពីជំនាន់ដើមមកអ្នកមីង។

ខ៖ ចាំ!ដែរគេទុកចោលពីជំនាន់ដើមមកនិង។

ក៖ បាទ!

ខ៖ ហើយកាលពីជំនាន់អាពតគេអត់វាយចោលទេ។

ក៖ បាទ! គេអត់វាយចោលទេអ្នកមីង។

ខ៖ ចាំ! ហើយវានៅដែរហើយវាជ្រកកោនដែរនិង។

ក៖ បាទ!វានៅដែរអ្នកមីង។

ខ៖ ចាំ!
វានៅដែរហើយដល់ពេលវារត់ទៅហើយដល់ពេលវៀតណាមគេមករំដោះពីពួកខ្មែរក្រហមចេញទៅ។

ក៖ បាទ!ៗ

ខ៖ ហើយវាមិននៅតាមឋានៈៗ។

ក៖ បាទ!

ខ៖ ហើយគេទៅតាមឋានៈៗប្រលោះៗអញ្ចឹងណាស់ហើយគេយកអាគារខ្មែរយើងនិង។

ក៖ បាទ! អាគារខ្មែរយើងនិងអ្នកមីង។

ខ៖ ហើយគេជួយការពារខ្មែរយើងណាស់។

ក៖ បាទ! គេជួយការពារខ្មែរយើងអ្នកមីង។

ខ៖ ចាំ!
ហើយអ្នកណាថាយួនអាក្រក់ខ្ញុំអត់ថាយួនអាក្រក់ទេដោយសារគេអត់ទាន់ជួបប្រទះអូន។

ក៖ បាទ!ៗដោយសារគេអត់ទាន់ជួបប្រទះហើយអញ្ចឹងគេអត់សូវដឹងអញ្ចឹងណាស់។

ខ៖ ចាំ! ដោយសារគេអត់ទាន់ជួបប្រទះហើយអញ្ចឹងគេចេះតែថាអញ្ចឹងទៅណាស់។ហើយទាល់តែជួបប្រទះទៅបានដឹង។

ក៖ បាទ! បានគាត់ដឹង។

ខ៖ ចាំ! ហើយគេជាអ្នកការពារខ្មែរហើយគេត្រឹមត្រូវណាស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំនិងកុំតែបានពួកវៀតណាមនិងបើករថពាដែកនិងដល់ទៅពីរហើយគេបើកផ្លូវឲ្យខ្ញុំដើរទៅហើយខ្ញុំពេលនិងនៅភូមិចាំរអា។

ក៖ បាទ!

ខ៖ ហើយដល់ពេលពួកវាបាញ់គ្នាប្រទូសប្រទះគ្នាអញ្ចឹងទៅហើយគេចូលរំដោះណាស់។

ក៖ បាទ!

ខ៖ ហើយវាមិនរត់ទៅក្នុងព្រៃហើយយើងមិនរត់ទៅតាមវាហើយយើងមានដឹងថាទៅណា។

ក៖ បាទ! នឹងហើយអ្នកមីងបើមិនរត់ទៅតាមគេទេមានតែស្លាប់ហើយអញ្ចឹងអ្នកមីងរត់ទៅតាមគេទៅអ្នកមីង។

ខ៖ ចាំ! ហើយចេះតែទៅតាមវាទៅណាស់បាត់ៗ។

ក៖ បាទ! មានចេះតែរត់ទៅតាមនិងហើយអ្នកមីង។

ខ៖ អឺនឹងហើយ។ហើយរត់បាត់ៗនិងហើយខ្ញុំនិយាយថាពេលនិងលំបាកណាស់អូនអើយអូន។

ក៖ បាទ!

ខ៖ ហើយខ្ញុំនៅដាំបាយតែនិង។

ក៖ បាទ! ហើយអញ្ចឹងពេលនិងអ្នកមីងមានអាយុប៉ុន្មានដែរអ្នកមីង?

ខ៖
ខ្ញុំពេលនិងខ្ញុំមានអាយុប្រហែលជាង១០ឆ្នាំហើយនិងហើយគ្រាន់តែដឹងអត់ពេលនិងខ្ញុំមានអាយុ១២ទៅ១៣ទេ។

ក៖ បាទ! ស

ខ៖
ហើយទើបបានមកដល់ឥឡូវនិងយើង៥៣ហើយ។ហើយបើពីជំនាន់អាពតមកដល់ឥឡូវនិងយើងបានប៉ុន្មានឆ្នាំដែរតាំងពីឆ្នាំ៧៩ហើយយើងរាប់ណាស់។

ក៖ បាទ!

ខ៖
ហើយ៧៩»៨០»៨១»៨២»៨៣»៨៤»៨៥»៨៦»៨៧»៨៨»៨៩»៩០»៩១»៩២»៩៣»៩៤»៩៥»៩៦»៩៧»៩៨»៩៩»២០០០។

ក៖ បាទ! ៩៩ហើយ២០០០។

ខ៖ ចាំ!
ហើយ២០០០គត់ហើយ២០០១»២០០២»២០០៣»២០០៤»២០០៥»២០០៦ហើយអញ្ចឹងវា២៨ឆ្នាំហើយណាស់។

ក៖ បាទ!

ខ៖ ហើយ២០០៦។

ក៖ បាទ! ហើយឥឡូវ២០១៨ហើយនិង។

ខ៖
ហើយអញ្ចឹង២០០៦»២០០៧»២០០៨»២០០៩»២០១០»២០១១»២០១២»២០១៣»២០១៤»២០១៥»២០១៦»២០១៧»២០១៨ហើយ២០១៨យើងដក២០ឆ្នាំ។

ក៖ បាទ!

ខ៖ ហើយអញ្ចឹងវា៣៦ឆ្នាំហើយ។

ក៖ បាទ!

ខ៖ ហើយអញ្ចឹង៣៦ឆ្នាំហើយ។ហើយដល់ពេលគេបែកព្រុលទៅ។

កៈ បាទ!

ខៈ ហើយយើងទៅៗហើយវាក៏រត់ចូលព្រៃបាត់ហើយដែរ។

កៈ បាទ!

ខៈ
ហើយយើងដឹងថាភៀសខ្លួនហើយយើងនាំគ្នាប្រគមគ្នាទៅហើយអ្នកខ្លះទៅបានអង្ករអីតិចតួចទៅណាស់។

កៈ បាទ!

ខៈ ហើយអញ្ចឹងណាស់។

កៈ បាទ! ហើយចែកគ្នាហូបពេញនិងទៅ។

ខៈ ចាំ! ហើយចែកគ្នាហូបអញ្ចឹងទៅហើយម្ដាយខ្ញុំពោះធំហើយទម្ងន់អារ៉ាតនិង។

កៈ បាទ! គាត់មានទម្ងន់ទៀត។

ខៈ ទម្ងន់អានាត។

កៈ គាត់ទម្ងន់កូនពៅអ្នកមីង។

ខៈ អត់ទេមិនមែនពៅទេមក។

កៈ បាទ! ហើយអញ្ចឹងបន្ទាប់អ្នកមីងមែនអ្នកមីង?

ខៈ មិនមែនបន្ទាប់ខ្ញុំទេទីប្រាំមួយនិង។

កៈ បាទ!គាត់ទីប្រាំមួយអ្នកមីង។

ខៈ ចាំ! ទីប្រាំមួយហើយជ្រកក្រោមដើមក្រសាំងអូនហើយ។

កៈ ហើយអញ្ចឹងឪពុកម្ដាយរបស់អ្នមីងគាត់នៅជាមួយគ្នា។

ខៈ ចាំ! គាត់នៅជុំគ្នា។

កៈ បាទ! គាត់នៅជុំគ្នា។

ខៈ គាត់នៅជុំគ្នាហើយខ្ញុំនិយាយតាំងពីដំបូងឲ្យស្ដាប់ណាស់។

ក៖ បាទ!

ខ៖ ហើយម៉ែឪពុកខ្ញុំគាត់នៅផ្ទះ។

ក៖ បាទ!

ខ៖ ហើយខ្ញុំនិងមិននៅក្រុមកុមារ។

ក៖ បាទ!

ខ៖ ហើយពេលដែលថាប៉ុលពតនិងវាវាយបែកខ្ញុំរត់ទៅរកម្ដាយខ្ញុំ។

ក៖ បាទ!

ខ៖ ហើយខ្ញុំរត់ទៅរកម្ដាយខ្ញុំហើយខ្ញុំរត់ចាក់ពីអញ្ចេកមកវិញ។

ក៖ បាទ!

ខ៖ ហើយខ្ញុំទៅហើយគេថាទៅនោះយើងឡើងទៅវិញណាស់។

ក៖ បាទ!

ខ៖
ហើយគេថាទៅវិញៗហើយទៅតាមនោះវិញហើយខ្ញុំទៅលួចកាច់អំពៅហើយពេលអត់ទាន់មានពេញទេ។

ក៖ បាទ!

ខ៖ ដល់ហើយគេចូលកាច់អំពៅ។

ក៖ បាទ!

ខ៖ ហើយខ្ញុំទៅកាច់អំពៅដែរហើយខ្ញុំបានបីដើមប្រវែងនិងៗណាស់។

ក៖ បាទ! អំពៅផ្អែមឬអំពៅសាងយើងនិងមែនអ្នកមីង។

ខ៖ អំពៅសាងនឹងហើយដូចថាគេដាំតាមមុខផ្ទះគេនិងណាស់។

ក៖ បាទ! គេដាំតាមមុខផ្ទះគេនិងអ្នកមីង។ហើយយើងកាច់យកហូបអញ្ចឹងទៅ។

ខ៖
នឹងហើយយើងកាចយកហូបនិងហើយ។ហើយខ្ញុំអូសមកហើយរត់កាត់ស្រែនិងហើយគេទើបតែស្លាប់ហើយអូន។

ក៖ បាទ!

ខ៖ វាទើបសម្លាប់ហើយវារត់ទៅបាត់ហើយណាស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំរត់មានទៅមើលអី។

ក៖ បាទ!

ខ៖ ហើយខ្ញុំចេះតែទៅៗហើយកាត់ស្រែហើយខ្ញុំជាន់ទៅណាស់។

ក៖ ហើយអញ្ចឹងអ្នកមីងរត់ទៅជាន់ទៅអ្នកមីង។

ខ៖ ចាំ!
ខ្ញុំគ្មានបានទៅមើលអីណាហើយម៉ាកាំបិតប្រតែអាពតនិងហើយខ្ញុំឃើញសុទ្ធតែឈាមនិង។ហើយវាទើបតែសម្លាប់ហើយនិង។

ក៖ បាទ!

ខ៖ ហើយយើងរត់ទៅ។

ក៖ បាទ! ហើយអញ្ចឹងអត់ដឹងអ្នកមីង។

ខ៖ ចាំ! យើងអត់ដឹងហើយយើងរត់ទៅកំពុងតែវាសម្លាប់និងយើងងាប់បាត់ហើយ។

ក៖ បាទ!

ខ៖ ហើយវាសម្លាប់ហើយវាលុបហើយវារត់ចោលចបនិង។

ក៖ បាទ! វារត់ចោលចបនិងអ្នកមីង។

ខ៖ ចាំ! វារត់ចោលចបនិងហើយអាកាំបិតស្នៀតអាពតនិងវាចាក់កនិង។

ក៖ បាទ!

ខ៖
ហើយនឹងហើយខ្ញុំថាលោកអើយលោកហើយខ្ញុំអញ្ជឹងណាស់ហើយខ្ញុំបន់លោកយាយលោកតាហើយហើយជួយខ្ញុំឲ្យរួចផុតពីនិងទៅលោក។

ក៖ បាទ!

ខ៖ ហើយខ្ញុំបន់អញ្ជឹងណាស់។

ក៖ បាទ!

ខ៖
ហើយអូនហើយពេលដែលរត់ទៅស្រាប់តែបានជួបអ្នកដែលស្គាល់និងហើយដូចថាពួកខ្ញុំមិនបញ្ជូនទៅស្វាយរៀងជិះរថភ្លើងនិង។

ក៖ បាទ!

ខ៖ ហើយបើអត់ជិះរថភ្លើងមានតែជិះកាប៉ាលនិង។

ក៖ បាទ!

ខ៖
ហើយដោយសារគេឲ្យយើងជិះនិងព្រោះអីវាឆាប់ដល់តែម៉ងហើយពេលនិងខ្ញុំបានមកដល់ផ្សារថ្មីយើងនិង។

ក៖ បាទ! ហើយអ្នកមីងបានមកដល់ផ្សារថ្មីយើងនិងអ្នកមីង។

ខ៖ ចាំ! ខ្ញុំបានមកដល់ផ្សារថ្មីនិងហើយគេឲ្យឡើងមកបានត្រឹមផ្សារថ្មីនិង។

ក៖ បាទ!

ខ៖
ហើយពេលបានមកដល់ផ្សារថ្មីនិងគេចែកអង្ករឲ្យទៅស៊ីហើយបានឡើងរថភ្លើងទៅបាត់ដំបងនិង។

ក៖ បាទ!

ខ៖ ហើយពេលនិងទៅបាត់ដំបងនិងទៅឈប់ទៅល្អាងនិង។

ក៖ បាទ! ហើយអញ្ជឹងជំនាន់និងមានរថភ្លើងទៀតអ្នកមីង?

ខ៖ ចាំ!មានតារថភ្លើងគ្រាន់តែគេដុតអុស។

ក៖
បាទ!មានដែលអ្នកមីងសម័យអាពតនិងអ្នកមីងហើយអញ្ចឹងកាលនិងគេដុតអុសអ្នកមីង?

ខ៖ ចាំ! កាលនិងគេដុតអុសនិងណាស់ហុយចុក។

ក៖ បាទ! ។

ខ៖ អឺគេដុតអុសពីក្រោយនិងណាស់។

ក៖ បាទ!
ហើយអញ្ចឹងកាលនិងគេអត់ដុតធ្យូងទេអ្នកមីង?ហើយអញ្ចឹងកាលនិងគេដុតអុសវិញអ្នកមីង?

ខ៖ ចាំ! ហើយអញ្ចឹងខ្ញុំឃើញវាហុយ។

ក៖ បាទ!
ហើយតាមខ្ញុំដឹងភាគច្រើនគេប្រើធ្យូងនិងទេអ្នកមីង។ហើយប្រហែលគេប្រើអុសផងធ្យូងផងអ្នកមីង។

ខ៖ ខ្ញុំប្រហែលអញ្ចឹងដែរនិងតែខ្ញុំឃើញតែកន្ទុលអុសអត់មានធ្យូងទេ។

ក៖ បាទ! ប្រហែលកាលនិងគេយកអុសទៅធ្វើធ្យូងនិងណាស់អ្នកមីង។

ខ៖ ចាំ!
អញ្ចឹងហើយបានក្រាស់និងហើយគេឲ្យយើងនិងទៅពីមុនគេហើយពេលដល់ម៉ោង៩គេឲ្យយើងស៊ីបាយនៅផ្សារថ្មីនិងហើយអង្ករគេគ្រាប់វែងៗ។

ក៖ បាទ!

ខ៖ អង្ករគ្រាប់គេវែងណាស់។

ក៖ បាទ! ហើយអញ្ចឹងអង្ករគេនិងអង្ករក្រហមមែនអ្នកមីង?

ខ៖ អត់ទេអង្ករយើងបាយសរទេ។

ក៖ បាទ! អង្ករយើងបាយសរនិងទេអ្នកមីង។

ខ៖ ចាំ! ហើយអង្ករនិងសរទេតែអង្ករស្រុកគេនិងវែងៗ។

កៈ បាទ!

ខៈ ប្រហែលនាងខុនអីនិង។

កៈ បាទ! គេឲ្យយើងញ៉ាំឲ្យឆ្អែតអ្នកមីង?

ខៈ ចាំ! គេឲ្យហូបឲ្យឆ្អែកៗទេ។

កៈ បាទ!

ខៈ ហើយចៃតដុនអីម៉ោង៣មិនទាន់ដល់ទេណា។

កៈ បាទ!

ខៈ ហើយប្រហែលម៉ោង៤ទៅម៉ោង៥បានដល់។

កៈ បាទ!

ខៈ ហើយយើងនិងមិនដាច់បាយ។

កៈ បាទ! នឹងហើយដាច់បាយហើយកាលនិង។

ខៈ ចាំ!
ហើយដាច់បាយហើយចៃតដុនអីយាយនិងគាត់លីងបាយគ្រៀមនិងទុកហើយគាត់ឲ្យបានតិចនិង។

កៈ បាទ! អ្នកមីងបានបាយគ្រៀមអ្នកមីង។

ខៈ ចាំ!
កាលនិងបានបាយគ្រៀមនិងហើយយាយនិងគាត់ថាគាត់លីងទុកខំអីអត់បាយនិង។

កៈ បាទ!

ខៈ
ហើយយាយនិងគាត់និងបានលីងបានតិចដែលទេហើយគាត់យកមកហុចឲ្យថៅៗនិង។

កៈ បាទ!

ខៈ ហើយមួយកន្ទប់ប៉ុណោកប្រហែលជាបីគីឡូនិង។

កៈ បាទ!

ខ៖ ហើយបានតែតិចនិងល្អហើយចេះបានទឹកផឹកនិង។

ក៖ បាទ! បានទឹកបានអីដែរអ្នកមីង។

ខ៖ ចាំ! ហើយគេចេះចែកទឹកឲ្យផឹកហើយខ្ញុំបានប្រមូលបានច្រើនដែរនិង។

ក៖ បាទ! ហើយអញ្ចឹងអ្នកមីងទឹកនិងជាទឹកសុទ្ធមែនអ្នកមីង?

ខ៖ ចាំ! នឹងទឹកសុទ្ធនិង។

ក៖ បាទ! ទឹកនាំចូលពីវៀតណាមមែនអ្នកមីង។

ខ៖ អត់ដឹងថាចេញពីផ្លូវណាទេ។

ក៖ បាទ!

ខ៖ ហើយគេឲ្យនៅផ្សារថ្មីយើងនិង។

ក៖ បាទ! ហើយអញ្ចឹងគេឲ្យមួយនាក់មួយដបទៅអ្នកមីង?

ខ៖ ចាំ! មួយនាក់មួយដបនិងទៅហើយដឹងឃើញនៅតាមផ្លូវណាស់។

ក៖ បាទ!

ខ៖ ហើយម្ដាយខ្ញុំគាត់បានទឹកមួយកំដុងនិងប្រហែលជា៥លីតនិងហើយ។

ក៖ បាទ!

ខ៖ ហើយបានទឹកនិងផឹកនៅលើនិងរហូតទៅណាស់។

ក៖ បាទ!

ខ៖ ហើយចែកគ្នាទៅហើយរថភ្លើងនិងម៉ោង៥បានដល់។

ក៖ បាទ!

ខ៖
ហើយពេលដែលដល់ទទួលគេចែកអង្ករអីខ្ញុំដូចជាភ្លេចហើយ។ហើយខ្ញុំអត់ចាំច្បាស់ដែរនិ
ង។

ក៖ បាទ!

ខ៖ ហើយម្តាយខ្ញុំគាត់មានឆ្នាំងអាវែងនិងគាត់មានទាន់ចោលណា។

ក៖ បាទ! ហើយអញ្ជឹងនៅបន្សល់ទុកអ្នកមីងណោះ។

ខ៖ មិនទាន់ចោលទេហើយខ្ញុំថាម៉ែកុំចោលណាម៉ែឆ្នាំងនិងឆ្នាំង៧៩ណាស់។

ក៖ បាទ! ឆ្នាំងបុរាណ។

ខ៖ នឹងហើយ។ហើយវាជម្រៅនាតប្រហែល១០កំប៉ុងណាស់។

ក៖ បាទ!

ខ៖ ចាំ! កាលពេលនិងដប់កំប៉ុងបានគ្រាន់ដាំស៊ីទាំងអស់គ្នាណាស់។

ក៖ បាទ! ហើយកាលពីជំនាន់និងភាគច្រើនគេធ្វើជ្រៅៗ។

ខ៖ ចាំ! នឹងហើយ។

ក៖ បាទ! គេទុកដាំបាយបានច្រើនៗ។

ខ៖ ហើយអូនហើយបើនិយាយពីបានបែកអាពតមកវិញណាស់។

ក៖ បាទ!ៗ

ខ៖ ហើយយើងនាំគ្នាហើយយើងអត់ដឹងហើយអត់ហេស។

ក៖ បាទ!

ខ៖ ហើយពេលឃើញទាហាននាំគ្នាទេពួនដើមត្នោត។

ក៖ បាទ!

ខ៖ ហើយទៅពួកដើមត្នោតហើយយួនថាឪៗ។

ក៖ បាទ! ឪនិងទៅអ្នកមីង។

ខ៖ ហើយវាឪទៅដៀងហើយដៀងនិងចុងក្រោយហើយឥឡូវនិងខ្ញុំចេះយួនហើយ។

ក៖ បាទ! ហើយអញ្ជឹងអ្នកមីងចេះភាសាវៀតណាមអ្នកមីង។

ខ៖ ចាំ! ឪៗហើយកាលណុងខ្ញុំអត់ទាន់ចេះណាស់។

កៈ បាទ!

ខៈ កាលពីជំនាន់អាពតនិងហើយយើងទៅលក់ជ្រូកនៅស្រុកខ្មែរយើងនិង។

កៈ បាទ!

ខៈ តែវាមកទិញលឺហើយមកទិញជ្រូកខ្មែរយើងនិង។

កៈ បាទ! ហើយអញ្ជឹងលក់នៅវៀតណាមមែនអ្នកមីង?

ខៈ លក់នៅខេត្តស្វាយរៀងយើងនិង។

កៈ បាទ!

ខៈ ហើយខ្ញុំទៅលក់ជ្រូកនិងនៅតាមផ្លូវឡើងទួលទៅវត្តសន្តិភាព។

កៈ បាទ! អ្នកមីងលក់ទៅវត្តសន្តិភាព។

ខៈ ចាំ!
ហើយគេជួលណាស់ហើយនៅពេលដែរដូចការម៉ៅការផ្ទះគេអញ្ជឹងណាស់។ហើយខ្ញុំទៅលក់នៅនិងទៅណាស់។

កៈ បាទ!

ខៈ ហើយអញ្ជឹងកាលនិងមួយនាក់មួយរយអីអញ្ជឹងទៅណាស់។

កៈ បាទ!

ខៈ ហើយយើងទិញនិងលក់និងហើយគេនិយាយយួន។

កៈ បាទ! ហើយអញ្ជឹងគេនិយាយយយួនអ្នកមីង?

ខៈ ហើយគេនិងចេញពីជំនាន់អាពតនិងហើយទទួលទៅហើយនាំគ្នាគេចយួនទៅ។

កៈ បាទ!

ខៈ ហើយស្រាប់តែយួនវានិយាយឌីដៀងឌីស្វាយរៀង។

កៈ បាទ!

ខៈ ហើយវាថាឌីនិងទៅដេកស្វាយរៀង។

កៈ បាទ!

ខៈ នឹងហើយស្រាប់តែទៅអូនហើយហើយទាមាត់ស្រះវាអាប្រលាយវា។

កៈ បាទ!

ខៈ អាប្រលាយមូលនិង។

កៈ ទាមែនអ្នកមីង?

ខៈ ទាហើយពេញតែត្រនុបនិងគ្មានអ្នកណាចាប់អូន។

កៈ បាទ!

ខៈ ចាំ! ហើយខ្ញុំអត់ហ៊ានចាប់ផងនិង។

កៈ បាទ! រត់តាប្រាសខ្លួនមិនបានផងនិង។

ខៈ ចាំ!ត្រូវហើយ។ហើយគ្មានអ្នកណាចាប់ទេហើយគេថាទៅផ្ទះនោះសុទ្ធតែប្រហុក។

កៈ បាទ!

ខៈ ចាំ! មានតែប្រហុកនិងអូនហើយមានតែទាំងឆ្អឹងនិង។

កៈ បាទ! ហើយអញ្ចឹងត្រីរាលមែនអ្នកមីង។

ខៈ អត់ទេត្រីកញ្ជាញច្រាស ។

កៈ បាទ! ត្រីកញ្ជាញច្រាសនិងអរត្រីតូចៗហើយជាប់ស្រនាញ់និងមែនអ្នកមីង។

ខៈ ចាំ!

កៈ បាទ! ត្រីអីដែលមានស្រកាៗរលិលនិងមែនអ្នកមីង?

ខៈ នឹងហើយ។ហើយគេគ្មានអីដាក់គេម្នាក់ៗនិងគេដាក់ជាយក្រមា។

កៈ បាទ! គេប្រើក្រមាអ្នកមីង។

ខៈ ចាំ! គេប្រើជាយក្រមានិង។

កៈ បាទ! ហើយអញ្ចឹងគេច្រូតយកតែម្តងអ្នកមីង។

ខ៖ ចាំ!
គេច្រូតយកតែម្តងនិងហើយវាមានស្រកាវាមុតដៃហើយខ្ញុំនៅតូចហើយយើងអត់យល់និង ហោស។

ក៖ បាទ!

ខ៖ ហើយខ្ញុំមុតដៃនិងហើយអូនអើយជាប់ដៃឡើងស្អាសអញ្ជឹងណាស់។

ក៖ បាទ!

ខ៖ ហើយដកមកនិងញ៉រសាច់ណាស់អូន។

ក៖ បាទ! ដកមកឈឺអ្នកមីង។

ខ៖ ចាំ! ខ្ញុំឈឺណាស់ហើយខ្ញុំដាក់ជាយក្រមា។

ក៖ បាទ!

ខ៖ ហើយសំណាងឪខ្ញុំថាកូនប្រហុកសុទ្ធតែឆ្អឹងណាស់កូនអើយ។

ក៖ បាទ!

ខ៖
ហើយខ្ញុំថាឪអើយចេះតែទ្រាំៗទៅស្ងោតចំហុយហើយដាក់ទឹកតិចទៅបានហើយឪអើយ។ ហើយយកទៅហូបទៅ។

ក៖ បាទ!ៗ

ខ៖ ហើយខ្ញុំទៅដល់ហើយខ្ញុំបេះស្វាយនៅព្រៃស្វាយនិង។

ក៖ បាទ!

ខ៖
ហើយទៅដល់ព្រៃស្វាយនិងហើយពេលខ្ញុំបានជិតដល់ព្រៃស្វាយនិងទៅហើយខ្ញុំដល់ថ្នាល់ ជាតិណាស់។

ក៖ បាទ!ជិតដល់ថ្នាល់ជាតិ។

ខ៖ វាទើបតែសម្លាប់ហើយនិង។

ក៖ បាទ! អាពតទើបតែសម្លាប់ហើយអ្នកមីង។

ខ៖ ចាំ!
ទើបតែសម្លាប់ហើយនិងហើយវាសម្លាប់និងនៅម្ដុំគមផ្កានិងហើយពេលវាសម្លាប់ហើយវាក៏រាប់ល្អម្ល៉េះហើយវាយកក្រមាយើងនិងគ្របមកហើយដាក់កទៅក្រោយហើយវាដាក់ដេកដំរាបគ្នានិងហើយដូចយើងដេកអញ្ចឹងអូន។ហើយគ្នាស្នាមឈាមទេអត់ដឹងថាធ្វើម្ដេចទេអូន។

ក៖ បាទ!

ខ៖ ហើយទាំងកូនខ្ចីនិងហើយដេកដាក់ដំរាបគ្នាអត់ដឹងថាគេសម្លាប់ម្ដេចទេ។

ក៖ ហើយអញ្ចឹងដេកប្រកាបមុខទៅអ្នកមីង។

ខ៖ អត់ប្រកាបទេ។

ក៖ បាទ! ហើយអញ្ចឹងផ្ងាលទៅអ្នកមីងហើយដូចយើងដេកធម្មតាទៅអ្នកមីង?

ខ៖ វាដាក់ឲ្យដេកផ្អៀងអញ្ចឹង។

ក៖ បាទ! ដេកផ្អៀងដូចយើងដេកលក់ទៅ។

ខ៖ ហើយដេកផ្អៀងដូចយើងដេកអញ្ចឹងណាស់។

ក៖ បាទ!

ខ៖
តែយើងថាពីយប់មិនណាស់យើងវាមិនដឹងណាស់យើងអត់ឃើញឈាមទេអូនដាក់ដំណៀបគ្នាអូនហើយថ្ពលជាតិមិនឡើងដីកំពស់តាវាមិនចឹងអូនអើយចឹងណាស់អូនមើដៃមីងណាស់តែវាអោយដាក់ដេកអញ្ចេកដូចរស់ចឹងណាស់គេមិនដឹងថាគេដេកហើយ។

ក៖ បាទ!មើទៅថាគេអស់កម្លាំងអីចឹងទៅតែពួកគាត់ស្លាប់បាត់?

ខ៖
ចាំ!ចឹងបានខ្ញុំថាអើយក្បាលនឹងធ្វើឆ្នាំងបាយដាក់ល្អីណៃនទាំងល្អីអោយទូលដាក់ល្អីនឹងហើយក្រមារនឹងជង១០មិនដឹង១២ឆ្នាំមិនដឹងទេប្រហែល១២ឆ្នាំហើយបងខ្ញុំឪខ្ញុំម៉ែខ្ញុំគាត់រុញអាទាសកាន់អង្ករ១បេលគាត់បានអង្ករ១បេល។

ក៖ បាទ!កាលនឹងបានអង្ករ១បេលនឹងប៉ុន្មានគីឡូអ្នកមីង៥០គីឡូឬក៏៣០គីឡូអ្នកមីង?

ខ៖ បាវទូតឆ្លើងអូនបាវពៅដើមបាវខ្មៅណាស់។

ក៖ បាទ!បាវខ្មៅធំៗ?

ខ៖ បាទ!ចេះតែជូតណាទេឪខ្ញុំទៅបានអង្ករនឹង១បេលរុញដាក់អន្ទៀសនឹងអូសណាស់។

ក៖ បាទ!ប្រហែលជា៥០ ៦០ គីឡូអ្នកមីង?

ខ៖
នឹងហើយប្រហែលពិននឹងឪខ្ញុំគាត់ជាអ្នកអូសខាងមុខដូចអាទៀសសេះចឹងណាស់ឪខ្ញុំគាត់អូសពីមុខម្ដាយខ្ញុំរុញខាងនេះបងខ្ញុំគាត់រុញខាងនេះខ្ញុំទូលឆ្នាំបាយហើយមកជំនាន់អាពតនឹងអាវ៉ាតនឹងកូនង៉ាអាយននឹងខ្ញុំទេមកពីនឹងមានតា៤នាក់ទេតែម្ដាយខ្ញុំគាត់មានប្អូនទៀត។

ក៖ អរចឹងមានតទៀតអ្នកមីង?

ខ៖ ចាំ!មកជំនាន់អាពតមានតា៤នាក់ទេមានតាពិននឹងមានអាថន អាយន
ខ្ញុំបងស្រីខ្ញុំមានតា៤នាក់ទេ។

ក៖ បាទ!មានតា៤នាក់ទេ?

ខ៖
ចាំ!នឹងហើយដល់ពេលទៅឪខ្ញុំឃើញគេចាប់កាបី៣ម៉ែឪខ្ញុំណាហើយម្ដាយខ្ញុំចាប់គេចាប់គ្រាប់គ្នាគេចាប់ពេញអាទៀសឪខ្ញុំអើញគាត់ចេះតែធ្វើណាស់ហើយចុះមានកង់មកពីណាដូចថាឈើចឹងទៅហើយចេះអោយក្របីវាអោះសទៅណាស់។

ក៖ បាទ!អោយចាប់ក្របីអូសទៅអ្នកមីង?

ខ៖
នឹងហើយចាប់ក្របីអោយទឹមអូសទៅហើយភួយនឹងបងខ្ញុំគាត់ជាអ្នកដឹកខ្ញុំជាអ្នកយួលឆ្នាំងបាយមុនដំបូងខ្ញុំដឹកផងយួលឆ្នាំងបាយផងហើយក្របីវាចេះតែគួតរកគ្នាទាញដោយចឹងដូលអុកគួតចឹងទៅម៉ែខ្ញុំគាត់ថាទាញយកមកម៉ែចងនឹងអាទៀសហើយគាត់រុញ៣នាក់ប្អូនខ្ញុំអាមួយនៅមុខពេទ្យស៊ីនឹងរាល់ថ្ងៃនឹងវាមេម៉ាយអាយុ៤០ឆ្នាំហើយ។

ក៖
បាទ!ចឹងអ្នកមីងពេលនៅពីក្មេងបងប្អូនអ្នកមីងគាត់ចូលចិត្តធ្វើអ្វីខ្លះជាមួយគ្នាអ្នកមីងដូចថាចូលចិត្តលេងអ្វីជាមួយគ្នាចឹងណាស់អ្នកមីង?

ខ៖
អតទេអត់ដែលមានពេលលេងផងនឹងកែរជីពីដើមសុទ្ធតែខ្ពួតគាលម៉ែខ្ញុំឪខ្ញុំគាត់នាំទៅគាលណាខ្ពស់ចឹងយើងគាលលើអោយវាជ្រៅណាស់ទប់ធ្វើភ្លឺស្រែទុបទឹកកាប់ឈ្នាលគ្មានពេលទំនេរទេអូនកូនអ្នកក្រមែនតែស្រោះគ្នាណាស់បងប្អូនខ្ញុំទៅលក់ទៅដល់ពេលលក់ទៅវៀ

តណាមវាប្រាប់យើងអោយយើងបេះត្រគួនមកដូរយកអង្ករយកទូតស្រលីក៏យកទៅខ្ញុំចង់ហូបពួតសំលីទៅដូរបាន៥កំពុងចឹងទៅយកមកលឹងហើយយកទៅដាំអីចឹងទៅណាស់។

កៈ បាទ!អ្នកមីង?

ខៈ ហើយគ្មានទេមិនដែលបានលេងអីទេមិនដែលមានពេលវេលាលេងទេ។

កៈ បាទ!ចឹងអ្នកមីងឪពុករបស់អ្នកមីងតើគាត់មានឈ្មោះអ្វីដែលអ្នកមីង?

ខៈ គាត់មានឈ្មោះ ទិច យ៉ាង។

កៈ អរចឹងគាត់ឈ្មោះទិច យ៉ាងអ្នកមីង?

ខៈ ចា៎!

កៈ បាទ!ហើយចុះម្ដាយវិញអ្នកមីង?

ខៈ ម្ដាយខ្ញុំគាត់ឈ្មោះ គុង យឿញ ។

កៈ អរម្ដាយអ្នកមីងគាត់ឈ្មោះ គុង យឿញចឹងតើគាត់នៅរស់សព្វថ្ងៃនឹងទេអ្នកមីង?

ខៈ នៅទាំងអស់។

កៈ អរចឹងពួកគាត់នៅទាំងអស់អ្នកមីង?

ខៈ ចា៎!

កៈ បាទ!ចឹងតោះគាត់មានអាយុប៉ុន្មានហើយសព្វថ្ងៃនឹងអ្នកមីង?

ខៈ គាត់៧៨អីម៉ែខ្ញុំគាត់ប្រហែល៧០ឆ្នាំហើយហើយឪខ្ញុំឥឡូវគាត់ធ្វើអាចារ។

កៈ អរឥឡូវឪពុកអ្នកមីងគាត់ធ្វើអាចារអ្នកមីង?

ខៈ ចា៎!គាត់ធ្វើអាចារនៅវត្តស្វាយរៀង។

កៈ អរបាត!ចឹងគាត់ធ្វើអាចារនៅវត្តស្វាយរៀងនឹងទៅអ្នកមីង?

ខៈ

ចា៎!គាត់ធ្វើអាចារនៅវត្តស្វាយរៀងនឹងនៅជិតផ្ទះគាត់ធ្វើអាចារខ្មោចអីចឹងទៅគេចេះតែមករកគាត់មកតាមគាត់គាត់ចេះតែធ្វើទៅ។

កៈ បាទ!ចឹងម្តាយរបស់អ្នកមីងគាត់នៅផ្ទះទៅ?

ខៈ
គាត់នៅផ្ទះមើក្របីតែឥឡូវគាត់លក់អស់ហើយក្របីនឹងណាស់តពីនឹងទៅនៅសល់ក្របី២មានកូនហើយក្របីនឹងវាចាស់ទៅគាត់ក៏លក់ទៅនៅសល់កូន១ក្រោលនឹងទៅដល់ឥឡូវគាត់ចែកកូនម្នាក់១ៗអស់ហើយគាត់ចែកអស់ហើយ។

កៈ បាទ!ចឹងអ៊ុំគាត់នៅរស់ទាំងអស់គ្នា?

ខៈ ចាំ!គាត់នៅរស់ទាំងអស់គ្នានឹង។

កៈ បាទ!ចឹងតើអ្នកមីងមាននៅចាំថាឪពុកអ្នកមីងកើតនៅថ្ងៃណាឆ្នាំណាខែណាទេអ្នកមីង?

ខៈ
ឪពុកខ្ញុំមិនដឹងទេបើខ្ញុំចាំតែមានសៀវភៅគ្រួសារតាទល់តែមានឈ្មោះគាត់ឈ្មោះឪពុកខ្ញុំឈ្មោះម្តាយខ្ញុំហើយបានមកយើង។

កៈ បាទ!ចឹងអ្នកមីងមានដឹងថាគាត់កើតឆ្នាំខ្មែរយើងណាស់ឆ្នាំណាដែលអ្នកមិង?

ខៈ ខ្ញុំមិនដឹងទេ។

កៈ បាទ!ចឹងអ្នកមីងអត់ដឹងទេអ្នកមីង?

ខៈ គាត់មុនលន់នល់ទៀតណាស់ដល់ពេលខ្ញុំមិនកើតលន់នល់ហើយខ្ញុំមិនដឹង។

កៈ បាទ!ចឹងម្តាយអ្នកមីងអត់ដឹងទេអ្នកមីង?

ខៈ ខ្ញុំអត់ដឹងដែលនឹង។

កៈ
បាទ!អ្នកមីងអត់ដឹងដែលចឹងអ្នកមីងគាត់មានបាននិយាយប្រាប់អ្នកមីងថាគាត់កើតនៅណាទេអ្នកមីង?

ខៈ ឪពុកខ្ញុំគាត់កើតនៅដែត។

កៈ បាទ!តើខេត្តអីគេដែលអ្នកមីង?

ខៈ ខេត្តស្វាយរៀងដែល។

កៈ បាទ!ស្វាយរៀងដែល?

ខ៖ ដដែតផ្សូត។

ក៖ អរដដែតផ្សូតអ្នកមីងបាទ?

ខ៖ ម្ដាយខ្ញុំគាត់នៅ អ៊ុងអាមនឹង។

ក៖ អរចឹងគាត់នៅខេត្តស្វាយរៀងដែលតាអ្នកមីង?

ខ៖
អ៊ុងអាមនឹងស្វាយរៀងដែលនឹងគាត់ចាំមើនេះផ្សូតចេញពីផ្សូតមកដដែតឪខ្ញុំចេញពីនឹងមក
ផ្លូវពុងរ៉ូមក។

ក៖ អរចឹងពួកគាត់អ្នកនៅស្រុកជិតគ្នាដែល?

ខ៖ ចា៎!នឹងហើយស្រុកជិតគ្នាតែថាគ្រាន់តែភូមិវាខុសគ្នាមួយដដែតមួយស្រុកអ៊ុងអាម។

ក៖
បាទ!មួយភូមិអ៊ុងអាមមួយទៀតភូមិដដែតបាទចឹងអ្នកមីងមានចាំថាគាត់ប្រកបមុខរបរអ្វីខ្លះ
ដើម្បីចិញ្ចឹមអ្នកមីងនឹងបងប្អូនអ្នកមីងតើឪពុកម្ដាយអ្នកមីងប្រកបមុខរបរអ្វីខ្លះអ្នកមីង?

ខ៖ ឪខ្ញុំណាស់។

ក៖ បាទ!

ខ៖ ឪខ្ញុំកាលឆ្នាំ៧៩នឹងមកឪខ្ញុំគាត់ធ្វើការនៅអគមន៍ខាងត្រាវ៉ូរជុសជូលថូល។

ក៖ បាទ!ចឹងម្ដាយអ្នកមីងវិញតើគាតយ់ប្រកបមុខរបរអ្វីដែលអ្នកមីង?

ខ៖ ម៉ែខ្ញុំគាត់លក់នំសម្សមយកមកអោយខ្ញុំទៅលក់។

ក៖
បាទ!ចឹងគាត់ដូចជាមេផ្ទះដែលពេលគាត់ទំនេលជាមេផ្ទះគាត់ធ្វើនំអោយអ្នកមីងយកទៅ
លក់ទៅ?

ខ៖ ចា៎!នឹងហើយគាត់អោយខ្ញុំចេញទៅលក់ចឹងទៅគាត់ទៅមើក្របី។

ក៖
បាទអរ!លោកឪពុកអ្នកមីងគាត់ជាអ្នកធ្វើត្រាវ៉ូលគាត់ចេះបារាំងច្រើហើយកាលជំនាន់នឹង?

ខ៖ ចា៎!ឪខ្ញុំគាត់ចេះតា។

ក៖ បាទ!ព្រោះកាលជំនាន់លន់នល់សុទ្ធតែបារាំងហើយភាសាបារាំងជាមុខ?

ខ៖ ចាំ!ឪខ្ញុំគាត់ចេះ។

ក៖
បាទ!ព្រោះឪពុកអ្នកមីងគាត់ជាអ្នកធ្វើត្រាវ៉ូរហើយបាទចឹងរាល់ថ្ងៃនឹងគាត់នៅចេះតាអ្នកមីង?

ខ៖ អរគាត់នៅចេះតារាល់ថ្ងៃនឹងតែឥឡូវគាត់ចេះធម៍វិញហើយ។

ក៖ បាទ!ចឹងឥឡូវគាត់ចេះធម៍វិញហើយបាទ?

ខ៖
គាត់ថាអញ្ចេកគាត់បង្រៀនពួកខ្ញុំដែលអោយពួកខ្ញុំបានចូលរៀនខ្ញុំចូលបាន៨៥ប្អូនខ្ញុំ៨៦ ៨៧
ហើយដល់ពេលគាត់ថារៀនអោយចេះគាត់ថាតិចទៀតគេជឿនលឿនណាស់កូនត្រូវតែខំប្រឹងរៀនគេបើករៀនអង់គ្លេសហើយ។

ក៖ អរគាត់អោយរៀនអង់គ្លេសទៀតបាទចឹងអ្នកមីងចេះភាសាអង់គ្លេសទៀត?

ខ៖
ខ្ញុំអតទេអង់គ្លេសខ្ញុំបានរៀនខ្លះៗដែលចេះតារាប់ស្រះទេអត់ទាន់ចេះច្រើនអីណាស់ណាទេ។

ក៖ អរចង់និយាយថាចឹងអ្នកមីងរៀនបានតិចទេអ្នកមីងចេះត្រឹមស្រះទេ?

ខ៖ ចាំ!នឹងហើយខ្ញុំប្រើវាមិនទាន់បានទេ។

ក៖
បាទ!ចឹងអ្នកមីងមាននៅចាំសាច់រឿងខ្លះពីឪពុកម្ដាយរបស់អ្នកមីងទេដូចថាគាត់ពីមុនមានការលំបាកអ្វីខ្លះគាត់ជួបនៅអ្វីខ្លះអីចឹងណាស់អ្នកមីងស្លូតបូតអីចឹងណាស់?

ខ៖
អរគាត់មិនដែលឈ្លោះជាមួយញាតិជិតខាងណាទេដូចថាគាត់បងរៀនកូនអោយខំប្រឹងរៀនសូត្រចឹងណាស់។

ក៖ បាទ!

ខ៖
ដូចថាគាត់ទៅស្ទុងទៅដក់អីចឹងណាស់គាត់ចេះតែលូងលូមកូនអោយកូនកុំខ្ជីព្រោះអីយើងក្រយើងខ្វីអត់មានអីស៊ីទេព្រោះឪខ្ញុំគាត់ទៅធ្វើការឪខ្ញុំកូន៩នាក់គេអោយកូនក្នុង១នាក់១០គីឡូ។

ក៖ អរអង្គរអ្នកមីង?

ខ៖
ចាំ!ក្នុងគ្រួសារខ្ញុំបាន៩០គីឡូអោយខ្ញុំធូរលុយបានតា៥ម៉ឺនទេអូនតែ៥ម៉ឺនឥឡូវនឹង៥ម៉ឺនមុនតើវាខុសគ្នាប៉ុន្មានទៅ។

ក៖ បាទ!៥ម៉ឺនមុនវាច្រើន?

ខ៖ ៥ម៉ឺនមុនស្មើ៥០ម៉ឺនយើងឥឡូវនឹងណាស់។

ក៖ បាទ!

ខ៖
ឪខ្ញុំដល់ពេលបើកមកចឹងទៅដឹកអង្គរមកហើយគាត់បានកង់បារាំងណាស់គេកង់មនុស្សប្រុសនឹងហើយបានកង់នឹងដឹកមកម្លែកជា២ដល់ពេលថ្ងៃ១នឹងគាត់ដូចថាធ្វើថ្នលមិនទៅតាមស្រុកភូមិទៀត។

ក៖ បាទ!នឹងហើយអ្នកមីង?

ខ៖ គេធ្វើពីទីរួមខេត្តទៅ។

ក៖ បាទ!គេធ្វើពីទីរួមខេត្តមួយទៅទីរួមខេត្តមួយទៀត?

ខ៖ ចាំ!ទៅដល់ចាភូអីចឹងណាស់ខ្ញុំឡើងទៅបើកលុយឪខ្ញុំណាស់។

ក៖ អរអ្នកមីងទៅបើកលុយ?

ខ៖
ទៅបើកលុយនឹងមានតាខ្ញុំទេទៅបើកលុយព្រោះបងខ្ញុំគាត់កាត់ដេរបងស្រីខ្ញុំនឹងណាស់។

ក៖ អរបងស្រីអ្នកមីងគាត់ជាជាងកាត់ដេរ?

ខ៖
គាត់កាត់ដេរគាត់ថាថានទៅបើកលុយគាត់មានអាក្រដាស់គេយកទៅបើកលុយណាស់។

កៈ បាទ!

ខៈ
ទៅបើកលុយគេថាចេះសញ្ញេលអត់គេចឹងណាស់ខ្ញុំថាអញ្ជែកខ្ញុំរៀបបានថ្នាក់ទី៣ដែលតា
ខ្ញុំមិនចេះសញ្ញេលមិចឪខ្ញុំសញ្ញេលខ្ញុំមិនដឹងឪខ្ញុំគាត់ដល់គាត់ទាញសញ្ញេលមួយផ្លែតហើ
យដល់ឥឡូវក៏និយាយដែលថាខ្ញុំសញ្ញេលដូចឪខ្ញុំដែល។

កៈ បាទ!បើអ្នកមីងនៅមើគាត់រហូត?

ខៈ ចាំ!ខ្ញុំចាំខ្ញុំឃើញគាត់ទាញម្នោកចឹងមកហើយម៉ង។

កៈ បាទ!ចឹងអ្នកមីងគាត់មានប្រាប់អ្នកមីងថាជីវិត្តគាត់កាលគាត់នៅពីក្មេងទេអ្នកមីង?

ខៈ
ដូចថាគាត់កាលនៅពីក្មេងគាត់អត់ទាន់បានគ្នាគាត់និយាយទៅឪខ្ញុំគាត់ម៉ែគាត់មេម៉ាយគា
ត់ថាគាតយ់ស៊ីឈ្នួលតាភ្នូរស្រែគេទេដូចថា១ហិតាអីចឹងហើយគេអោយគាត់ប៉ុន្មានចឹងណា
ស់។

កៈ បាទ!

ខៈ
ដល់ពេលទៅស៊ីឈ្នួលផ្ទះម៉ែខ្ញុំទទួលម៉ែខ្ញុំនឹងមេម៉ាយឪគាត់ណាស់គាត់មានតាឪគាត់អត់
មានម្ដាយម៉ែខ្ញុំគាត់អាយុ១៥ឆ្នាំឪខ្ញុំគាត់អាយុ១៨ឆ្នាំម៉ែខ្ញុំគាត់ការទាំងពីអាយុ១៨ឆ្នាំម៉ែខ្ញុំនឹង
ខ្ញុំអង្គុយជិតគ្នា៣នាក់បងខ្ញុំគេថាបងប្អូនរវល់តាអាធំខ្ញុំវាថាអញ្ជែកអ៊ុំខ្ញុំម៉ែហើយនឹងឪបងប្អូ
នគ្នាហើយដល់អាធំវាថាអញ្ជែកបាត់៣នាក់បងប្អូននឹងទៅណាគាត់លក់ជ្រូកទៅគាត់ទិញ
សំពត់អោយបងខ្ញុំនឹងពណ៍ក្រាប់អំពិលខ្ញុំនឹងពណ៍ខៀវសំពត់សឹងណាស់ឥឡូវនេះគាត់ចែ
កយកមកអោយខ្ញុំនេះ។

កៈ បាទ!ចឹងអ្នកមីងមានចាំឈ្មោះជីដូនជីតារបស់អ្នកមីងទេ?

ខៈ អរខាងឪខ្ញុំមែន។

កៈ បាទ!ខាងឪនឹងខាងម្ដាយណាស់អ្នកមីង?

ខៈ ខាងឪខ្ញុំឈ្មោះ តា ទិច ម្ដាយគាត់ឈ្មោះ យាយ អីយ
កូនខ្ញុំម៉ែខ្ញុំចាប់ជាតិណាស់មកសុំខ្ញុំនៅណាស់គាត់ស្រលាញ់ខ្ញុំណាស់។

កៈ បាទ!ចឹងខាងម្ដាយអ្នកមីងវិញណាស់?

ខ៖ ខាងម្ដាយខ្ញុំឈ្មោះ តា ទិម យាយ អែម។

ក៖ បាទ!តា ទិម យាយ អែម?

ខ៖
ចាំ!ខ្ញុំចាំបានតាយាយក្រោយទេយាយមុនខ្ញុំកើតអត់ទាន់ទេខ្ញុំនោះពិននឹងណាស់យកខ្ញុំទៅមើលណាស់ផ្ដាច់ដោះចឹងណាស់គាត់ម៉ោង៤គាត់ឡើងទៅសួតធម៍ដល់ថ្ងៃមុននឹងខ្ញុំទៅចូលឆ្នាំនៅស្វាយរៀងនឹងណាស់។

ក៖ បាទ!

ខ៖
ខ្ញុំថាមីងទាំងអស់គ្នានឹងណាស់បើមាននាក់ណាជាប់សសៃចង្កេសសសៃខ្នងអីនឹងណាស់ប្រាប់ខ្ញុំចាប់អោយមីង។

ក៖ បាទ!ចឹងអ្នកមីងចេះចាប់សសៃទៀត?

ខ៖
ចាំ!ចុះមីងអ្នកលក់អង្ករនឹងគាត់ចាបអោយខ្ញុំតាបានខ្ញុំស្គាល់គ្នាទិញអង្ករនឹងខែមុន១បេលដល់ហើយមីងខ្ញុំដេកនឹងគាត់ថាអញ្ចេកផ្ទះមីនឹងតគ្រកូរចឹងណាស់តគ្រកូរពីតាខ្ញុំណាស់ដូចថាតាខ្ញុំពីមុនគាត់គ្រូខ្មែរ។

ក៖ អរគាត់គ្រូខាងចាប់សសៃចាប់អីចឹងទៅ?

ខ៖
ចាំ!ចាប់សសៃធ្លូមស្គាសអីណាស់ដុសថ្នាំខ្មែរអាថ្នាំខ្មែរយើងពីដើមមិនដោះសកាលពីដើមដុសណាស់អូន។

ក៖ បាទ!

ខ៖
គាត់ទុកអោយម្ដាយខ្ញុំគាត់ថាដំណាងអោយខ្ញុំដល់ហើយមីងគាត់ថាដំណាងមែនគាត់ថាចឹងណាស់មីងខ្ញុំគាត់ថាប្អូនម៉ែខ្ញុំណាស់គាត់ថាដំណាងមែនដំណាងខ្ញុំថាមុននឹងចាប់ណាស់ដុតធូបអោយខ្ញុំ៥សសៃសិនដល់ហើយគាត់ថាកុំភ័យ។

ក៖
បាទ!ចឹងអ្នកមីងមាននៅចាំឆ្នាំដែលគាត់កើតទេអ្នកមីងហើយគាត់កើតនៅណាអីចឹងណាស់អ្នកមីង?

ខ៖ គាត់កើតនៅនឹងគាត់កើតនៅស្វាយរៀងនឹង។

ក៖ បាទ! ហើយអញ្ចឹងគាត់កើតនៅស្វាយរៀងនិងអ្នកមីងហើយអញ្ចឹងជីដូនជីតារបស់អ្នកមីង?

ខ៖ គាត់នៅស្វាយរៀងនឹង។

ក៖ បាទ! ហើយអញ្ចឹងខាងឪពុកខាងម្ដាយគាត់នៅស្វាយរៀងនិងទៅអ្នកមីង។

ខ៖ ហើយគាត់នៅនិងទាំងពីរនិងឪខ្ញុំតាដែតហើយនិងម្ដាយខ្ញុំអូមអាមនិង។

ក៖ បាទ! ហើយអញ្ចឹងលោកឪពុករបស់អ្នកនៅតាដែតហើយម្ដាយរបស់អ្នកមីងនៅអូមអាម។

ខ៖ ចាំ! គាត់នៅទីរួមខេត្ត។

ក៖ បាទ! ដូចថាគាត់នៅជនបទណា។

ខ៖ ចាំ! នឹងហើយគាត់នៅនិងធ្លាក់ដល់ផ្សូតហើយនិងជនបទនិង។

ក៖ បាទ!

ខ៖ ហើយបើផ្ទះម៉ែនៅរាល់ថ្ងៃនិងគាត់នៅងុយតាបែក។

ក៖ បាទ!

ខ៖ ហើយនិងគេហៅជិតទីរួមខេត្តហើយ។

ក៖ បាទ!

ខ៖ ហើយនិងចូលទីរួមខេត្តស្វាយរៀងហើយ។

ក៖ បាទ! ហើយអញ្ចឹងអ្នកមីងមានដឹងខ្លះពីរឿងរបស់ពួកកាលគាត់នៅខេត្តស្វាយរៀងនិងណាស់ថាគាត់មានការលំបាកដែលបានចិញ្ចឹមឪពុករបស់អ្នកមីងអញ្ចឹងណាស់អ្នកមីង?

ខ៖ ហើយគាត់ធ្លាប់ទៅស៊ីឈ្នួល។

ក៖ បាទ! ហើយអញ្ចឹងគាត់ធ្លាប់ទៅស៊ីឈ្នួលគេដែរអ្នកមីង។

ខ៖ ចាំ! គាត់ធ្លាប់ស៊ីឈ្នួលភ្ជួរស្រែគេទៅ។

កៈ បាទ! ហើយអញ្ចឹងគាត់ប្រាប់ដែរអ្នកមីង?

ខៈ ចាំ! គាត់ប្រាប់ដែរតាហើយគាត់និយាយប្រវត្តិគាត់មកប្រាប់យើងតា។

កៈ បាទ!
អត់ទេអ្នកមីងប្រវត្តិជីដូនជីតារបស់អ្នកមីងណាស់។ហើយអញ្ចឹងលោកឪពុករបស់អ្នកមីងមានបានប្រាប់ទេថាគាត់មានការជួបលំបាកអីអញ្ចឹងណាស់អ្នកមីង?

ខៈ ហើយគាត់ថាគាត់ពិបាកហើយយាយនិងគាត់ស្រឡាញ់ម៉ែខ្ញុំ។

កៈ បាទ!

ខៈ
ហើយគាត់ស្រឡាញ់ម្ដាយខ្ញុំដល់ហើយយាយខ្ញុំនិងគាត់ប្ដឹងហើយតាខ្ញុំថាទុកមួយឆ្នាំទៅវាឡើង១៥។

កៈ បាទ!

ខៈ ហើយវាឲ្យឈានចូល១៦។

កៈ បាទ!ៗ

ខៈ ហើយគ្រូនិងគេហៅហារារបស់គេនិងគេទាយដឹង។

កៈ បាទ!

ខៈ
ហើយម្ដាយខ្ញុំទៅបម្រើមួយឆ្នាំហើយគាត់បានការហើយដល់ពេលការហើយនិងហើយគាត់បានឲ្យខ្ញុំមកនៅស្រុកកំណើតនាតអត់ទេខ្ញុំច្រលំទេ។

កៈ បាទ!

ខៈ ហើយគាត់បានមកទីរួមខេត្តស្វាយរៀងណាស់។

កៈ បាទ!

ខៈ ហើយអ្នកជាស្រុកទន្លេហើយអញ្ចឹងបានមកទៅតាមទន្លេ។

កៈ បាទ! គាត់ជាអ្នកស្រុកទន្លេអ្នកមីង?

ខៈ ចាំ!ហើយគាត់ឲ្យចេញឲ្យមកនៅស្រុកកំណើតជីដូនជីតា។

កៈ បាទ!

ខៈ ហើយគាត់ឲ្យទៅនៅផ្ទះទន្លេ។

កៈ បាទ!

ខៈ ហើយគាត់ថាគាត់មានកេរ្តិ៍និងនៅមួយ។

កៈ បាទ!

ខៈ ហើយអញ្ជឹងទៅគាត់នៅស្រែអញ្ជឹងទៅ។

កៈ បាទ!

ខៈ ហើយគាត់នៅទន្លេនិងទៅណាស់។

កៈ បាទ!

ខៈ ហើយគាត់មកនិងហើយបានខ្ញុំប្អូននាក់និង។

កៈ បាទ!

ខៈ ហើយពេលដែលខ្ញុំបានបែកពីជំនាន់អាពតនិងគេយកពួកខ្ញុំទៅជំលៀសទៅ។

កៈ បាទ!

ខៈ ហើយខ្ញុំនិងបងខ្ញុំនិងនៅខាងត្បូងទេហើយម្តាយខ្ញុំគាត់បងខ្ញុំនិងមើលខ្ញុំនិង។

កៈ បាទ!

ខៈ
ហើយខ្ញុំនៅជាមួយបងនិងហើយខ្ញុំលីទិកកែវាស្រែកនិងហើយខ្ញុំរកចុះបានមុនហើយបងខ្ញុំនិងរត់ពីក្រោយនិងហើយជាន់អាសំពត់យើងចងរឹតនិងហោស។

កៈ បាទ!

ខៈ ហើយខ្ញុំចង្កាខ្ញុំមានផ្លែទាល់ឥឡូវនិងព្រោះអីចង្កាខ្ញុំនិងអុកនិងកាំជណ្តើរនិង។

កៈ បាទ!

ខៈ ហើយនិងកាំជណ្តើរឈើនិង។

កៈ បាទ! ហើយអញ្ចឹងអ្នកមីងបានប្រាប់ខ្ញុំថាក្រុមគ្រួសារអ្នកមីងទាំងអស់និងនៅខេត្តស្វាយរៀងនិងទាំងអស់គ្នានិងទៅ។

ខៈ ចា៎! ជាអ្នកស្វាយរៀងនិង។

កៈ បាទ! ហើយអញ្ចឹងអ្នកមីងមានសាច់ញ្ញាតិនៅក្រៅប្រទេសទេអ្នកមីងហើយដូចសាច់បងប្អូនជីដូនមួយហើយជីទួតមួយនៅក្រៅប្រទេសអ្នកមីង?

ខៈ មាន។

កៈ បាទ! មានអ្នកមីងនៅប្រទេសណាដែរអ្នកមីង?

ខៈ មានប្អូនម្ដាយខ្ញុំគាត់នៅអាមេរិច។

កៈ បាទ! ហើយអញ្ចឹងគាត់នៅអាមេរិចអ្នកមីង។

ខៈ ចា៎!

កៈ ហើយអញ្ចឹងគាត់នៅណាដែរអ្នកមីងនៅអាមេរិចនិងណាស់។ហើយអញ្ចឹងនៅរដ្ឋអីគេដែរអ្នកមីង?

ខៈ អត់ដឹងថារដ្ឋអីគេដែរទេខ្ញុំអត់ដឹងដែរនិង។

កៈ បាទ! អត់ដឹងថារដ្ឋអីទេ។

ខៈ ខ្ញុំដែលបានអំណាយអីទេ។

កៈ គេអត់ដែលមកលេងទេអ្នកមីង?

ខៈ គេអត់ដែលមកលេងទេ។

កៈ ហើយអញ្ចឹងម្ដាយឪពុករបស់អ្នកមីងបានប្រាប់អ្នកមីងថាមានបងប្អូននៅអាមេរិច។

ខៈ ចា៎! ហើយប្រាប់ខ្ញុំថាមានប្អូននៅអាមេរិចម្នាក់។

កៈ បាទ!

ខៈ ហើយគាត់ថាប្អូនគាត់។

កៈ បាទ! ហើយអញ្ចឹងប្អូនគាត់បង្កើតអ្នកមីង។

ខៈ ចាំ! ឈ្មោះអីទេភ្លេចទៅណាស់។

កៈ បាទ!

ខៈ ហើយគាត់ហៅថាឪអាម៉ៅៗ។

កៈ បាទ!ហើយអញ្ចឹងគាត់ប្រុសមែនអ្នកមីង?

ខៈ គាត់និងប្រុស។

កៈ បាទ!

ខៈ ហើយគាត់បែកតែប្រពន្ធរបស់គាត់នៅនិងរាល់ថ្ងៃនិងតា។

កៈ បាទ! ហើយអញ្ចឹងអ្នកមីងបើនិយាយពីអាពាហ៍ពិពាហ៍របស់អ្នកមីងវិញហើយអញ្ចឹងស្វាមីរបស់អ្នកមីងមានឈ្មោះអីគេដែរអ្នកមីង?

ខៈ គាត់មានឈ្មោះថា ប៉ែន សុខុន។

កៈ បាទ! គាត់មានឈ្មោះ ប៉ែន សុខុនអ្នកមីង?

ខៈ ចាំ!

កៈ បាទ! ហើយអញ្ចឹងអ្នកមីងប្តីរបស់អ្នកមីងគាត់រស់នៅនិងដែរអ្នកមីង?

ខៈ គាត់ស្លាប់ហើយតា។

កៈ បាទ! ហើយអញ្ចឹងគាត់ស្លាប់ហើយអ្នកមីង។

ខៈ ចាំ! ហើយគាត់ស្លាប់តាំងពីអាយុ៣៦ឆ្នាំ។

កៈ បាទ! ហើយអញ្ចឹងគាត់ស្លាប់យូរហើយអ្នកមីង?

ខៈ ចាំ! គាត់ស្លប់យូរហើយនិងហើយគាត់ស្លាប់តាំងអាយុ៣៦មក។

កៈ បាទ! ហើយអញ្ចឹងអ្នកមីងគាត់ស្លាប់ដោយសារអីដែរអ្នកមីង?

ខៈ ហើយគាត់ស្លាប់ទឹកនោមផ្អែម។

កៈ បាទ! ហើយអញ្ចឹងគាត់ស្លាប់ដោយសារទឹកនោមផ្អែមនិងអ្នកមីង?

ខៈ ចាំ! ហើយគាត់ឡើងជាតិស្ករខ្លាំងណាស់។

កៈ បាទ! គាត់ឡើងជាតិស្ករច្រើនអ្នកមីង។

ខៈ ចាំ! ហើយអូនអាណិតគាត់ណាស់ហើយកាលពីជំនាន់និង២០០៩ណាស់។

កៈ បាទ!

ខៈ ហើយកាលនិងមួយយប់ប្រាំម៉ឺនៗដូចគេរាប់អញ្ចឹងណាស់។

កៈ បាទ!

ខៈ ហើយគាត់រកបានហើយគាត់ស៊ីឈ្នួលបងខ្ញុំណាស់។

កៈ បាទ!

ខៈ ហើយបងថ្លៃខ្ញុំនិងដឹកជ្រូកពីវៀតណាមមកនិង។

កៈ បាទ!

ខៈ ហើយដូចឆ្កកអញ្ចឹងណាស់ហើយមួយថ្ងៃគេឲ្យពីនេះពីនោះអញ្ចឹងណាស់។

កៈ បាទ!

ខៈ ហើយយកមកសន្សំហើយមកធ្វើផ្ទះខ្លួនឯងនិងណាស់។

កៈ បាទ!

ខៈ ហើយនិង៣៥០ទិញដីគេនិងហើយគេចាំដីប្រហែលប៉ុនឡានទូរីសនិង។

កៈ បាទ!

ខៈ ហើយនិងឈើនិងហើយជើងសសរពឺនកដៃនិង។

កៈ បាទ!

ខៈ ហើយយើងអត់ណាស់ហើយយើងទិញយកតែដីទៅ។

កៈ បាទ! ហើយអញ្ចឹងអ្នកមីងមានចាំថ្ងៃខែឆ្នាំកំណើតរបស់គាត់ទេអ្នកមីង?

ខ៖ ឆ្នាំកំណើតគាត់មែន?

ក៖ បាទ! ហើយអញ្ជឹងអត់ដឹងថាគាត់ឆ្នាំណាទេអ្នកមីង?
ខ៖ មិនដឹង!

ក៖ ហើយអញ្ជឹងឆ្នាំខ្មែរយើងនិងមានចាំទេអ្នកមីង?

ខ៖ បើឆ្នាំខ្មែរឆ្នាំ ច និង។

ក៖ បាទ! បើឆ្នាំខ្មែរឆ្នាំ ច អ្នកមីង?

ខ៖ ចាំ!

ក៖ បាទ!
ហើយអញ្ជឹងអ្នកមីងបើនិយាយពីអាពាហ៍ពិពាហ៍របស់អ្នកមីងនិងពេលការនិងបានប្រហែលជាប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ ខ្ញុំការនិងតាំងពីឆ្នាំ៩១។

ក៖ បាទ! បានយូរដែរអ្នកមីងតាំងពីឆ្នាំ៩១។

ខ៖ ចាំ! ហើយគាត់ដណ្តឹង៩០។

ក៖ បាទ! ដណ្តឹង៩០អ្នកមីង?

ខ៖ ចាំ! គាត់ដណ្តឹងទុកហើយដណ្តឹងទុកដូចម្តាយខ្ញុំដែរនិង។

ក៖ បាទ! គាត់ដណ្តឹងអ្នកមីងឲ្យហើយអ្នកមីង។

ខ៖ ចាំ! ហើយខ្ញុំពេលនិងខ្ញុំ២០គត់ដែរនិង។

ក៖ បាទ! ហើយអញ្ជឹងអ្នកមីងមានចាំថាថ្ងៃណាខែណាទេអ្នកមីង?

ខ៖ ពេលការនិងមែន។

ក៖ បាទ!

ខ៖ ការនិងខែ០៩ ។

ក៖ បាទ!ការខែ ០៩ហើយអញ្ជឹងថ្ងៃទីប៉ុន្មានដែរអ្នកមីង?

ខ៖ ការខែ ០៩ថ្ងៃអាទិត្យនិង។

ក៖ បាទ! ពេលនិងអ្នកមីងការថ្ងៃអាទិត្យអ្នកមីង?

ខ៖ ចាំ!

ក៖ ហើយពេលនិងឆ្នាំ៩១។

ខ៖ ចាំ! ៩១ហើយខ្ញុំនៅរៀននិង៩០គត់។

ក៖
ហើយអញ្ចឹងអាពាហ៍ពិពាហ៍របស់អ្នកមីងនិងបានរៀបចំដោយឪពុកម្ដាយរបស់អ្នកមីងឬក៏អ្នកមីងបានឃើញគ្នាហើយបានស្រឡាញ់គ្នាអ្នកមីង?

ខ៖ អត់ទេកាលណុងអត់បានស្រឡាញ់គ្នាផងនិង។

ក៖ បាទ! ហើយអញ្ចឹងម្ដាយឪពុកអ្នកមីងជាអ្នករៀបចំឲ្យអ្នកមីង។

ខ៖ អត់ទេតាមខ្សែរយៈមីងខ្ញុំទេ។

ក៖ បាទ! តាមខ្សែរយៈមីងអ្នកមីងទេ។

ខ៖ ហើយខ្ញុំទៅលក់ត្រីងៀត។

ក៖ បាទ!

ខ៖ ហើយដល់ហើយម្ដាយគាត់និងលក់ត្រីងៀតដែរអញ្ចឹងណាស់។

ក៖ បាទ! ហើយអញ្ចឹងអ្នកមីងអ្នកលក់ត្រីងៀតជាមួយគ្នា។

ខ៖ ចាំ! ហើយទទួលមីងខ្ញុំនិង។

ក៖ បាទ!

ខ៖ មីងខ្ញុំនិងប្អូនម្ដាយខ្ញុំនិងជីដូនមួយទេ។

ក៖ បាទ!

ខ៖ មិនមែនបង្កើតទេហើយគាត់នៅផ្ទះជិតផ្ទះយាយនិង។

ក៖ បាទ! គាត់នៅផ្ទះជិតផ្ទះយាយនិង។

ខ៖
ហើយនឹងហើយ។ហើយគាត់មកផ្សារនិងហើយគាត់យួរធូន់ពេកហើយគាត់ថាមីហានហើយអញទុកផ្ញើរនិងផងហើយអញទៅទិញទៀត។

ក៖ បាទ!

ខ៖ ហើយអញ្ជឹងណាស់។

ក៖ បាទ!

ខ៖ ហើយដល់ហើយម្ដាយក្មេកខ្ញុំនិងគាត់លក់ម្ហូនិងនៅក្បែរខ្ញុំដែរ។

ក៖ បាទ!

ខ៖ ហើយខ្ញុំលក់ត្រីងៀតនៅនិងដែរហើយគេមានតូបហើយខ្ញុំលក់តាមក្រោមដីនិង។

ក៖ បាទ!

ខ៖ ហើយម្ដាយក្មេកខ្ញុំនិងគាត់ពឹងមីងខ្ញុំ។

ក៖ បាទ!

ខ៖ ហើយគាត់និយាយសារបាហើយប៉ុន្តែហើយគាត់ស្គាល់ប្រវត្តិប្ដីខ្ញុំហើយនិង។

ក៖ បាទ!

ខ៖ ដល់ហើយគាត់ថាពឹងឲ្យមីងខ្ញុំនិងទៅសួរម្ដាយខ្ញុំ។

ក៖ បាទ!

ខ៖ ដល់ហើយគាត់ថាគេនៅណាគេនៅណីហើយម្ដាយមីយួនហើយគេហៅអញ្ជឹងណាស់។

ក៖ បាទ!

ខ៖
សួរគាត់ថាមានអីអាខនគេបិនរក់ស៊ីចង់ងាប់គេតាមឡានជ្រូកតាំងពីគេនៅក្មេងនៅកំលោះមេសណាស់ដល់ពេលខ្ញុំការប្ដីខ្ញុំអាយុ១៩ឆ្នាំទេ។

ក៖ បាទ!ចឹងអ្នកមីងពេលនឹងអាយុប៉ុន្មានដែលអ្នកមីង?

ខ៖ ពេលនឹងខ្ញុំអាយុ២០ឆ្នាំ។

កៈ បាទ!ចឹងពេលនឹងប្អូនអ្នកមីងទៀត?

ខៈ
ចា៎!ដល់ពេលប្អូនខ្ញុំ១ឆ្នាំដល់ពេល២១ឆ្នាំបានខ្ញុំការវាឃ្លងគ្នាណាស់គេប្ចូកទៅវាឃើញ៩១
៩០គតម៉ែឪខ្ញុំគាត់អត់អោយខ្ញុំរៀបការទេនៅដើរទៅស្ទុងដល់វៀតណាមណាស់ទលដែន
វៀតណាមដូចថាយើងទៅចាប់១ដីចឹងណាស់បើគាត់អត់ទៅតាមឡានជ្រូកទេគាត់ទៅតាម
យើងដែលទៅស្ទុងដែលគាត់ថាថ្ងៃនឹងគាត់ទៅដែលចឹងណាស់គាត់ជិះកង់បងគាត់គេមាន
ប្រពន្ធគេបានកង់១បងគាត់ខាងហ្វូតប្រស៊ីរ។

កៈ អរបាទ!គាត់ជាអ្នកយកថាស៊ីរ?

ខៈ ចា៎!ដូចថាគេសន្សំទៅគេបានកង់ជិះណា។

កៈ បាទ!

ខៈ ដល់ហើយម៉ែខ្ញុំនឹងគាត់ទៅលក់ដូរទៅគាត់ទិញកង់អោយខ្ញុំបាន១ដែរ។

កៈ បាទ!ចឹងអ្នកមីងស្វាមីអ្នកមីងជូនចំណូនដល់ឪពុកម្តាយអ្នកមីងប៉ុន្មានដែលអ្នកមីង?

ខៈ គាត់ជូនឪពុកម្តាយខ្ញុំតា៩៣ាន់នឹង។

កៈ អរបាទ!ចឹងជូនចំណូនដល់ឪពុកម្តាយអ្នកមីងតា៩៣ាន់រៀលទេ?

ខៈ ចា៎!តា៩៣ាន់រៀលនឹងស្មើនឹង៩ម៉ឺនយើងឥឡូវនឹងណាស់។

កៈ បាទ!នឹងហើយអ្នកមីង៩៣ាន់សម័យមុនថ្លៃ?

ខៈ
ម៉ែខ្ញុំគាត់មានតា៥ម៉ឺនគាត់ឡើងផ្សារបានតែសាច់គោ១សាច់ជ្រូក១សាច់គោនឹងទិញចិញ្ចឹម
ទេតែវាអត់កូនណាផ្ទាល់ចឹងណាគាត់ធ្វើគោ១ជ្រូក១ស៊ីតែឯងទៅ។

កៈ
បាទ!ពេលអ្នកមីងការនឹងតើបានត្រឹមសែនទេឬមួយអ្នកមីងធ្វើពិធីហៅភ្ញៀវហៅអីអ្នកមីង?

ខៈ
ការត្រឹមត្រូវមានភ្ញៀវមានអីត្រឹមត្រូវអត់បានថតទេទទួលបងប្អូនមានម៉ាស៊ីនថតដែលតែគេ
អត់បានយកទៅ?

កៈ បាទ!គេអត់បានយកទៅ?

ខ៖
ចា៎!ហើយទទូលទៅកក់គេជាបគេ១កន្លែងទៅកក់ជាងថតណាគេមានតា១កន្លែងដល់ហើយគេជាប់គេកក់មុនយើងណាដល់ពេលចឹងទៅអត់បានថត។

ក៖
បាទ!ចឹងអ្នកមីងដំបូងឡើយណាស់ដែលអ្នកមីងបានជួបប្តីអ្នកមីងណាស់តើអ្នកមីងទៅជួបគ្នានៅណាដែលអ្នកមីងដូចថាជួបគ្នាពេលធ្វើស្រែជាមួយគ្នាបាននិយាយគ្នាអីទេអ្នកមីង?

ខ៖ អត់ទេខ្ញុំអត់ដែលបានជួបគ្នាផងនឹង។

ក៖ បាទ!ចឹងឃើញមុខគ្នារៀបការម៉ងអ្នកមីង?

ខ៖
នៅពេលឃើញមុខគ្នានឹងអញ្ចេកដំបូងមីងខ្ញុំនឹងគាត់ទៅសួរអោយម៉ែក្មេកខ្ញុំនឹងពឹងអោយទៅសួរអោយៗទៅដល់ហើយគាត់និយាយភិនភាគដល់ហើយគេនិយាយចឹងខ្ញុំថាអរខ្ញុំស្គាល់ហើយស្គាល់គ្នាតែមិនដែលនិយាយរកគ្នាទេខ្ញុំទៅការប្អូនខ្ញុំជីដូនមួយដែលនៅប្រទេសក្រៅនឹងណាហើយគេនឹងមិត្តភក្តិខាងបងប្អូនជីដូនមួយខ្ញុំនឹងអាពៅនេះគេទៅការដែលដល់ហើយគេនិយាយភិនភាគទៅដល់ហើយអរមួយអីស្គមកោងខ្នងនឹងខ្ញុំថាចឹងណាស់ហើយដល់ពេលទៅខ្ញុំថាអរមួយនឹងហើយកាលជំនាន់នឹងគេពាក់តាមួកហេលរ៉ូណាមួកមូលគេកាត់ហើយគេមិនដេរគេពាក់មួកនឹងដល់ហើយគេថាអរមួយអីពាក់មួកស្គមកោងខ្នងនឹងខ្ញុំនិយាយចឹងណាស់ដល់ហើយគេពាក់ខោស្តូលស្គមណាមានអីស្ងិតៗដល់ហើយមីងខ្ញុំគាត់ថាអញ្ចេកនឹងឈ្មោះ ខន
ខ្ញុំថាចឹខ្ញុំមិនស្គាល់ខ្ញុំស្គាល់តាំងឈ្មោះទៀតតែខ្ញុំមិនដែលនិយាយរកគ្នាទេដល់ពេលពេលហើយថ្ងៃនឹងគេចង់ឃើញខ្ញុំគេយកបាយយកមកអោយម្តាយគេ។

ក៖ បាទ!នឹងហើយគាត់ចង់ជួបអ្នកមីង?

ខ៖
ចា៎!នឹងហើយតែមីងខ្ញុំមិនទាន់សួរខ្ញុំទេណាអត់ទាន់អោយខ្ញុំដឹងទេគេលួចមើរៀងខ្លួនអីចឹងណាស់ដល់ហើយគេយកបាយមកដល់ហើយគាត់និយាយថានេះម៉ែបាយគាត់និយាយសំឡេងធំណាស់ថ្ងៃនឹងគេដាក់បាយពីស្រាក់មក។

ក៖ អរគាត់ដាក់២ស្រាក់មកគាត់ញ៉ាំនៅនឹងដែលអ្នកមីង?

ខ៖
ដល់ហើយខ្ញុំថាមីអូនម៉ែក្មេកខ្ញុំហៅណាមីអូនទៅទិញតាម្ហូបមកមិនចាប់បាត់ទិញបាយទេបាយអុី២ស្រាក់ហើយដល់ពេលទៅខ្ញុំទិញបាយមកខ្ញុំគិតនៅក្នុងចិត្តថាអរមួយនឹងហើយ

ហើយគាត់នឹងក៏អៀនខ្ញុំដែលគេដើរចេញគេទៅបាត់គេទុកបាយគេដើរទៅបាត់ទៅទិញបាយខ្ញុំហូបហើយខ្ញុំហូបបាយខ្ញុំចេះតែអស់សំណើតសើតដល់ពេលហើយពួកគ្នាខ្ញុំណាថាមិនដឹងទៅរឿងអីទេនោះថាអោយខ្ញុំចឹងណាស់ហើយចុះក្មេងៗដូចគ្នាអាយុ១៥ឆ្នាំអីនឹង។

កៈ
បាទ!ចឹងអ្នកមីងតើអ្នកមីងមានចេះសសេរភាសាខ្មែរនឹងចេះងានភាសាខ្មែរបានខ្លះៗទេអ្នកមីង?

ខៈ ខ្ញុំមិនសូវចេះប៉ុន្មានទេឥឡូវនឹងខ្ញុំចង់ភ្លេចខ្លះៗហើយ។

កៈ បាទ!ចឹងក្រៅពីភាសាខ្មែរតើអ្នកមីងមានចេះភាសាបទេសដូចជា បារាំង ថៃ វៀតណាម អង់គ្លេស អីតើអ្នកមីងមានចេះភាសាមួយណាដែលអ្នកមីង?

ខៈ
ខ្ញុំចេះភាសាវៀតណាមដែលចេះតិចនឹងចេះថាយើងបើកប្រែលគេទិញអីទិញអីចឹងណាស់បើថាអក្សរគេខ្ញុំមិនចេះទេ។

កៈ
បាទ!ចឹងក្រៅពីភាសាវៀតណាមតើអ្នកមីងមានចេះភាសាអ្វីក្រៅពីភាសាវៀតណាមនឹងទេអ្នកមីង?

ខៈ មានតាពិននឹងខ្ញុំចេះ?

កៈ បាទ!ចឹងអ្នកមីងចេះតាភាសាវៀតណាមបានខ្លះៗទេ?

ខៈ
ចាំ!ព្រោះយើងរកស៊ីជាមួយវៀតណាមដូចថាវៀតណាមមកតថ្លៃជ្រូកមួយតម្លៃប៉ុន្មាន(គេនិយាយភាសាវៀតណាម គុង ហៀវ មួយ កាន់ យូវ)។

កៈ បាទ!

ខៈ
គេថាមួយនឹងតម្លៃប៉ុន្មានខ្ញុំសួរគេថាគេនិយាយថាមិចគេថាមួយនឹងតម្លៃប៉ុន្មានចឹងណាស់(គេនិយាយភាសាវៀតណាម ហៀវ ដឹក យូវ )
ឈ្មោលនឹងតម្លៃប៉ុន្មានដល់ហើយខ្ញុំចេះតែចាំទុកណាស់ខ្ញុំចេះតែតហើយខ្ញុំចេះតែចាំទុកណាស់ប្ដីខ្ញុំគាត់ចេះចឹងដែលតា។

កៈ បាទ!គាត់ចេះដែល?

ខ៖
ចាំ!តែគាត់ចេះនិយាយរូលម៉ងបើម៉ែក្មេកខ្ញុំគាត់រឹតតែចេះជាងនឹងទៀតដល់ខ្ញុំគ្រាន់ចេះភាសាបកប្រែល (គេនិយាយភាសាវៀតណាម មុខ បឹង យូ មុខបឹង ណាម ចាំ
)មួយដប់ប៉ុន្មានមួយដប់៥រយចឹងណាស់ដូចថាម្ហូរគេហៅអី (គេហៅ ម៉េ) ដេគៀសគេហៅអី (វ៉ែត) ចេកគេហៅអី (ជួយ) ខ្ញុំចាំណាស់ទៅ។

ក៖ បាទ!ចឹងអ្នកមីងបើនិយាយពីភាសាវិញតើអ្នកមីងរៀនបានថ្នាក់ទីប៉ុន្មានដែលអ្នកមីង?

ខ៖ ខ្ញុំរៀនបានថ្នាក់ទី៥បានពាក់កណ្ដាលឆ្នាំទេ។

ក៖ បាទ!ចឹងអ្នកមីងរៀនបានត្រឹមថ្នាក់បឋមទេអ្នកមីងណាស់?

ខ៖ នឹងហើយចូលបឋមរៀនបានថ្នាក់បឋម។

ក៖
បាទ!ចឹងអ្នកមីងមានចាំថាសាលាដែលអ្នកមីងរៀនកាលជំនាន់នឹងតើមានឈ្មោះអ្វីហើយនៅណាដែលអ្នកមីង?

ខ៖ សាលាលីសេគេហៅសាលាឈ្មោះ សាលា លីសសេ។

ក៖ បាទ!ចឹងតើនៅណាដែលអ្នកមីង?

ខ៖ ទីរួមខេត្តស្វាយរៀង។

ក៖ អរចឹងអ្នកមីងរៀននៅទីរួមខេត្តស្វាយរៀងនឹង?

ខ៖ ចាំ!កាលមុនកំរិត១ថ្នាក់ទី៣ ៤ យើងប្រលងខ្ញុំប្រលងដូចថាគេយកពិន្ទុស
២៤ចឹងខ្ញុំជាប់បានពិន្ទុស២៣
ហើយដល់ពេលចឹងគេអោយយើងរៀនបន្តទៀតតែដល់ឆ្នាំយើងអត់បានប្រលងទេយើងឡើងម៉ងគេថាជាប់ជាថាពរ។

ក៖
បាទ!ចឹងអ្នកមីងក្នុងពេលដែលអ្នកមីងនៅរៀននឹងនៅក្នុងភូមិណាស់តើអ្នកមីងមានមិត្តភក្តិជិតស្និតទេដូចថាធ្លាប់ដើរលេងជាមួយគ្នាទៅណាអីជាមួយគ្នាចឹងណាស់អ្នកមីងលក្ខណៈថាចិត្តមួយថ្លើមមួយណាស់អ្នកមីងតើមានទេអ្នកមីង?

ខ៖ ខ្ញុំមានតែមនុស្សប្រុស។

ក៖ អរមនុស្សប្រុសចឹងអ្នកមីងចូលចិត្តដើរលេងជាមួយមនុស្សប្រុសអ្នកមីង?

ខ៖ នឹងហើយយើងចាប់ទុកជាមិត្តភក្តិណាស់នឹងមួយហើយស្រីឈ្មោះ ធារ នី តែគ្នាកើតអេតន៍ស្លាប់ទៅខ្ញុំអានិតវាណាស់តែធារ នីនឹងអា រ៉ាយនឹងវាឈ្មោះ អារ៉ាយពេលមកពីភូមិខ្ញុំនឹង២នាក់អារ៉ាយហើយគ្រូគេដាក់អោយយើងដាំដំណាំដាំផ្កាណា ហើយដូចថាមានកម្មវិធីនៅមហាស្របចឹងណាស់គេយកនាក់ដែលដាំផ្កានឹងយកខ្ញុំមួយហើយនឹងធារ នី យកទៅជូនបាត់ផ្កាកណះធិតីនៅមហាស្រប។

ក៖ បាទ!ចឹងអ្នកមីងតើអ្នកមីងមានធ្លាប់ស៊ីឈ្នួលដក់ស្ទុងអោយគេទេអ្នកមីង?

ខ៖ ខ្ញុំធ្លាប់តាមួយថ្ងៃបាន៥ពាន់។

ក៖ អរអ្នកមីងធ្វើបានមួយថ្ងៃបាន៥ពាន់អ្នកមីង?

ខ៖ អត់ទេស្ទុងទៅស្ទុងអោយពីណាទេកាលនឹងយកលុយគេមុនខ្ញុំថាអោយលុយខ្ញុំមុនមកបានខ្ញុំទៅស្ទូងអោយ។

ក៖ បាទ!ចឹងអ្នកមីងពេលអ្នកមីងនៅពីក្មេងរហូតមកដល់ធំនឹងតើអ្នកមីងមានការផ្លាស់ប្តូរអ្វីខ្លះដែលអ្នកមីងនៅក្នុងជីវិត្តរបស់អ្នកមីងណាស់?

ខ៖ ខ្ញុំចង់និយាយម៉ែខ្ញុំគាត់ចំអកអោយខ្ញុំគាត់សួរថាឥឡូវមានប្តីហើយតើនៅធ្វើស្រែអត់គាត់សួរចឹងណាស់។

ក៖ បាទ!

ខ៖ ខ្ញុំថាអរខ្ញុំឈប់ហើយខ្ញុំរៀងហើយខ្ញុំហត់ណាស់។

ក៖ បាទ!

ខ៖ ទៅស្រែទូលបាយដក់សំរាបហត់ណាស់គេដក់នឹងស្រទឹកខ្លួនផងខ្ញុំច្រូកទាំងក្បាលហើយបើច្រូកស្រូវនេះមើដៃខ្ញុំណាស់កាត់កន្ទោមនឹងប្រហែលជា៥ ៦ ៧អស់មុតដដែលៗដូចថាចង់ប្រហោយនៅសល់តែ២គមចឹងម៉ាខ្វាកម៉ាលឿនណាស់លឿនដៃម៉ែខ្ញុំគាត់ថាហើយម្តាយខ្ញុំគាត់មិនដែលមុតមួយខ្ញុំទេមុតៗជាងគេហើយដក់សំណាបលោកអើយច្ចូកខ្លួនអស់ហើយម៉ងតាហើយ។

ក៖ បាទ!ចឹងអ្នកមីងបើនិយាយពីមុខម្ហូបវិញតើអ្នកមីងចូលចិត្តម្ហូបអីគេដែលអ្នកមីង?

ខ៖ ខ្ញុំចូលចិត្តតាចៀន។

ក៖ អរចៀនសាច់ជ្រូកសាច់គោអីទៅអ្នកមីង?

ខ៖ ចាំ!ចៀនសាច់ជ្រូក។

ក៖ បាទ!ចឹងសម្លម្ជូលតើអ្នកមីងចូលចិត្តទេ?

ខ៖ សម្លម្ជូលប្រលិត ម្ជូលត្រួនអីខ្ញុំចូលចិត្តសម្លសម្លកអីខ្ញុំចូលចិត្តសម្លសម្លក។

ក៖
បាទ!ចឹងអ្នកមីងបើនិយាយពីល្បែងប្រជាប្រិយវិញតើអ្នកមីងចូលចិត្តលេងល្បែងប្រជាប្រិយដូចជា បោះឈូង ទាញព្រាត់ បោះអង្គុញ លក់កន្សែង
អីនឹងតើអ្នកមីងចូលចិត្តមួយណាដែលអ្នកមីង?

ខ៖ ខ្ញុំចូលចិត្តលេងបោះឈូង។

ក៖ អរអ្នកមីងចូលចិត្តលេងបោះឈូងអ្នកមីង?

ខ៖
នឹងហើយកាលនៅពីក្មេងខ្ញុំចូលចិត្តលេងបោះឈូងអរខ្ញុំលាត់ចាប់មុនគេគេរាប់មិនទាន់ទេ
ខ្ញុំទៅមុនគេហើយ។

ក៖ បាទ!ចឹងអ្នកមីងចូលចិត្តរាំហើយចឹង?

ខ៖
អរខ្ញុំចូលចិត្តរាំណាស់អោយតាផ្លែតនឹងគេហៅឡើងរាំហើយចូលរាំដូចអាប៉ាយចឹងណាស់
ចេញពីផ្ទះពីនាក់អាប៉ាយចឹងធារ នីគេនៅផ្សារដល់ហើយជុំគ្នាតា៣នាក់នឹងគេអោយដាំផ្កា។

ក៖ បាទ!ចឹងអ្នកមីងចូលចិត្តច្រៀងទេ?

ខ៖ ខ្ញុំចូលចិត្ត។

ក៖
បាទ!អ្នកមីងចូលចិត្តច្រៀងចឹងអ្នកមីងចូលចិត្តបទចម្រៀងមួយណាដារាមួយណាដែលអ្នកមីងចូលចិត្តច្រៀងតាមណាស់អ្នកមីងដូចជា អ្នកស្រី ហ៊ឹម ស៊ីវ៉ន អ្នកស្រី រស់
ស្រីសោភាអីនឹងណាស់អ្នកមីង?

ខ៖
ខ្ញុំចូលចិត្តហ៊ិមស៊ីវ៉នតែខ្ញុំអត់ច្រៀងទេខ្ញាស់គេបទសិលាចាំប្តីហើយនឹងទុំទាវកាលមុនធុងបាស់ទិញមកធូរដែលនឹងប្តីខ្ញុំទិញមកដល់ពេលផ្ទះខ្ញុំមានកណ្តុលច្រើនវាឡើងកាត់ឡើងអីក៏ខូតទៅនេះអាវ៉ាយវាសុំវាថាខ្ចីទេយកទៅយូរៗទៅខ្ញុំថាលែងចង់ហើយសរាប់ចាក់អីខ្ញុំទុបតែលក់តាសន្សំលុយអីទិញម៉ងបានខ្ញុំមិននិយាយទេកំសត់ណាស់ពេលខ្ញុំមកភ្នំពេញយើងធ្លាក់ខ្លួនណាស់ការនៅស្វាយរៀងខ្ញុំធ្វើជ្រូកលក់ដំបូងលក់ជ្រូកនៅរស់ជ្រូកហែរទឹកហែរបាយនឹងណាស់ជ្រូកញីជ្រូកឈ្មោលនឹងដល់ពេលទៅជ្រូកគេងាប់អាជ្រូកនឹងណាស់គេថាទិញបាន២
៣ហើយគេថាអាខនយកទៅសុខចិត្តចឹងណាស់ដល់ហើយជ្រូកងាប់នឹងគេចាក់កគេសួរថាលក់ប៉ុន្មានជ្រូកមួយ៨ម៉ឺន៧ម៉ឺនចឹងទៅហើយយើងធ្វើលក់ទៅបាន១៥ម៉ឺនបែកខ្ញែកគ្នាតាំងពីនឹងមកខ្ញុំអរគុណពូខិលនឹងឈ្មោះ ពូ ខិល គាត់និយាយវៀតណាម
ក៏គាត់ចេះចិនក៏គាត់ចេះគាត់ចិនណាគាត់កាប់ជ្រូកណាគាត់ឈ្មោះពូខិលគេតាចឹងគាត់មិនដឹងថាស្លាប់ឬក៏អត់ទេកាលនឹងខ្ញុំនៅនឹងគាត់អាយុ៥០ឆ្នាំជាងហើយ។

ក៖ បាទ!

ខ៖
ហើយប្តីខ្ញុំគាត់ហៅតាបងទេខ្ញុំហៅពូហើយអ្នកលក់សាច់ជ្រូកក៏ដោយអ្នកដឹកជ្រូកក៏ដោយចូលចិត្តតាខ្ញុំទេគាត់ចូលចិត្តលេងនិយាយមួយមាត់មុខវារៀងកញ្ជ្រចឹងបើខ្ញុំនិយាយលេងសើតនឹងចេះតែសើតហើយមួយមកចូលចិត្តតាខ្ញុំទេលេងសុទ្ធតែកៀកកខ្ញុំទៃហើយប្រពន្ធៗគាត់ថាលេងនឹងប្រយ័ត្នអាខនប្រច័ណហើយប្តីខ្ញុំគាត់ថាអញ្ចែកអរមិនដឹងប្រច័ណអីទេគាត់និយាយសំឡេងធំអ្នកណាក៏ចូលចិត្តខ្ញុំដែលមួយទ្រុងជ្រូកពូកគាត់សប្បាយចិត្តណាស់។

ក៖
បាទ!ចឹងអ្នកមីងបើនិយាយពីឧបត្តន៍តន្ត្រីវិញតើនៅក្នុងគ្រួសារអ្នកមីងបងប្អូនអ្នកមីងនិយាយរួមទៅសាច់ញ្ញាតិរបស់អ្នកមីងទាំងអស់គ្នានឹងណាស់តើមានអ្នកណាគេដែលចេះឧបត្តន៍តន្ត្រីដូចជា ស្គរ យីតា ចាប៉ី ខ្លាឈ្មូរ រនៀត តើមានទេអ្នកមីង?

ខ៖
ឪខ្ញុំគាត់ជាអ្នកលេងភ្លេងការមិត្តភក្តិគាត់ក៏ជាអ្នកលេងភ្លេងការដែលដល់ហើយទៅជាមិត្តភក្តិចឹងទៅខ្ញុំក៏ហៅឪដែលចាំឪខ្ញុំឈ្មោះ ឪរឹតមិត្តភក្តិឪខ្ញុំនឹងណាឈ្មោះ
ឪរឹតនៅស្រុកដដែតនៅស្រុកឪខ្ញុំនឹងគាត់កើតនៅនឹងទាំងអស់គ្នាហើយគាត់ប្រគមតន្ត្រីខាងភ្លេងការដល់ភ្លេងការទៅទទួលឪខ្ញុំគាត់រៀបការអីហើយចឹងទៅកាលគាត់ពីកំលោះគាត់ដើរលេងភ្លេងការណាជាមួយគ្នាហើយដល់ពេលមានប្រពន្ធមានអីចឹងទៅតាខ្ញុំនឹងអោយគេរមកនៅស្រុកខេត្តស្វាយរៀងនឹងហើយឪខ្ញុំនឹងគាត់ជាអ្នកលេងភ្លេងការប្រពៃណីហើយទុប

តែចោពេលគាត់ធ្វើអាចារនឹងទេគេអោយគាត់អាត្រែតណាស់ម៉ោង៩គាត់ឡើងគួសទ្រលេងភ្លេងការហើយម្ដាយខ្ញុំគាត់ថាអររកតាដេកមិនបានទេ។

ក៖
បាទ!ចឹងអ្នកមីងលក្ខណៈថាផ្ទះរបស់អ្នកមីងដែលរស់នៅតាំងពីក្មេងរហូតមកដល់ធំពីសម័យមុនណាស់តើមានសាភាពលក្ខណៈមិចដែលអ្នកមីងផ្ទះក្បឿងឬក៏ផ្ទះមិចដែលអ្នកមីង?

ខ៖ ផ្ទះបិតដី។

ក៖ ផ្ទះបិតដីអ្នកមីង?

ខ៖
ចាំ!ផ្ទះស្វាយរៀងផ្ទះបិតដីផ្ទះតាអ្នកណាអត់ផ្ទះបិតដីហើយជាប់នឹងច្បើងបិតដីណាស់ដូចថាជាន់ច្បើងជាន់ភូកៗចឹងទៅរូយចឹងទៅចន់រូតហើយយើងរៃអានៀបយើងរំលងពិននឹងរូតហើយចន់ភូកៗទៅបាលយកមកដាក់ពេលជួយគ្នាទៅនាក់ស្រុកនឹងគេជួយគ្នាណាស់។

ក៖ បាទ!ចឹងដំបូលគេដាក់អីគេដែលអ្នកមីង?

ខ៖ ដំបូលការនឹង។

ក៖ ដំបូកសង័សីមែនអ្នកមីងកាលនឹង?

ខ៖
អត់ទេមិនមែនទេដំបូលស្លឹកតាទិញស្លឹក១រយដបណាស់ឃើញគេដេអត់ស្លឹកគេដេរណាស់១រយដប១ម៉ឺន៥ពាន់។

ក៖ បាទ!ចឹងជញ្ជៀងវិញអ្នកមីង?

ខ៖ ជញ្ជៀងនឹងបិតដីដែល។

ក៖ អរជញ្ជៀងបិតដីដែលបើអានៀបវិញអ្នកមីង?

ខ៖ អានៀបជាប់ដីនឹងដូចថាយើងធ្វើមានបានលើកអីធ្វើផ្ទាល់ដី។

ក៖ បាទ!ចឹងអ្នកមីងផ្ទះនឹងតើអ្នកមីងធ្វើខ្លួនឯងឬមួយក៏អ្នកមីងជួរគេធ្វើអ្នកមីង?

ខ៖ ស្រុកនឹងអត់មានជួរទេពីដើមណាស់។

ក៖ អរចឹងអ្នកជិតខាងគេមកជួយធ្វើគ្នាទៅ?

ខ៖ ចាំ!ជួយគ្នាទៅវិញទៅមកណាស់។

ក៖ បាទ!ជួយគ្នាទៅវិញទៅមក?

ខ៖
យើងទៅផ្ទះរកគេមកអោយជួយចឹងណាស់រួតហើយយើងដាំបាយដំណើបអោយគេហូប ទៅបាយដំណើបជាមួយត្រីងៀត។

ក៖ បាទ!ចឹងសភារះវិញអ្នកមីងនិយាយហើយមានពូថៅអីទៅអ្នកមីង?

ខ៖
មានពូថៅអីមកកាន់យកមករៀងៗខ្លួនគេជួយយើងយើងជួយគេហើយបើនិយាយពីកូនខ្ទីវិញណាស់ជុំវិញគ្នាមកជួយសំរាទល់ភ្លឺដូចគ្នាមានតែស្រា៥លីតទេផឹកទៅ។

ក៖
បាទ!ចឹងអ្នកមីងដូចថាអ្នកមីងបានប្រាប់ខ្ញុំថាម្ដាយរបស់អ្នកមីងចេះធ្វើសម្បុមចឹងតើអ្នកមីងមានចេះធ្វើនំសម្បុមនឹងដូចគាត់ទេអ្នកមីង?

ខ៖
ខ្ញុំចេះតាខ្ញុំមកនៅនឹងខ្ញុំធ្លាប់ធ្វើម្ដងកាលឆ្នាំ២០០០គតណាស់គេ៣មិនអោយយើងវិតសម្បុមតាមផ្ទះខ្ញុំទិញអង្ករមួយគីឡូហើយប្ដីខ្ញុំថាអញ្ចេកវិតចេកផងនឹងវិតសាចជ្រូកផងទៅគាត់ជាអ្នកទិញមកខ្ញុំចូលផ្សារថ្មីទិញស្លឹកនៅផ្សារថ្មីបានមានទិញផ្សារថ្មីមកខ្ញុំនៅលក់នៅបេនឡានម៉ោង១២បានប្ដីខ្ញុំមកដឹកខ្ញុំការគាត់នៅរស់ណាស់គាត់ទៅដឹកថ្ងៃនឹងគាត់អត់ទៅវៀតណាមទេគាត់អត់ទៅដឹកជ្រូកនៅវៀតណាមទេដល់ពេលខ្ញុំមកដល់គាត់ចាក់ត្រាមមុនហើយគាត់កិនអង្ករគាត់ធ្វើចឹងណាស់កាលនឹងនៅក្រោមផ្ទះធ្វើអីនៅក្រោមផ្ទះចឹងណាស់ហើយដល់ពេលទៅខ្ញុំវិតសម្បុមហើយចឹងដូចថាអ្នកជិតខាងគេអត់មានចឹងយើងអោយគេខ្លះចឹងណាស់។

ក៖
បាទ!អ្នកមីងចឹងតើនៅពេលណាដែលអ្នកមីងពិបាកជាងគេនៅក្នុងជីវិត្តរបស់អ្នកមីងណាស់តើពេលណាដែលអ្នកមីង?

ខ៖
មកនៅភ្នំពេញនឹងណាស់៩៥ប្ដីខ្ញុំគាត់ធ្វើការសំណងខ្ញុំមានកូន២នាក់ហើយកូនទី១កើត៦ឆ្នាំ៩២កូនទី២កើត៩៤មកកូនពៅនឹងកើត២០០៤គាត់ស្លាប់២០០៥។

កៈ
បាទ!ចឹងអ្នកមីងពេលនៅពៅក្មេងណាស់តើអ្នកមីងមានគោរបំណងប្រាថ្នាថានៅពេលអ្នកមីងធំឡើងចង់ធ្វើដូចជា គ្រូពេទ្យ គ្រូបង្រៀន
អ្វីៗផ្សេងៗចឹងណាស់អ្នកមីងតើអ្នកមីងមានគោបំណងចង់ធ្វើអ្វីដែលអ្នកមីង?

ខៈ ខ្ញុំចង់រកស៊ី។

កៈ អរអ្នកមីងចង់រកស៊ី?

ខៈ
ចាំ!ខ្ញុំចង់រកស៊ីខ្ញុំថាធ្វើការបានប្រាក់ខែតិចទេខ្ញុំគិតចឹងណាស់ខ្ញុំមើតាឪខ្ញុំបានប្រាក់ខែតា៥ម៉ឺនមិនស្មើខ្ញុំលក់លៀសមួយកញ្ឆេលផងនឹងខ្ញុំទៅលក់ត្រីងៀតដំបូងខ្ញុំទិញគេលក់ជាមួយគេណាស់ខ្ញុំរៀនពេលល្ងាចខ្ញុំលក់មួយព្រឹកចឹងខ្ញុំលក់បាន១គីឡូ៣គីឡូបើលក់ដាច់ទៅបាន៥គីឡូ១០គីឡូទៅទទួលមួយទិញត្រីងៀតខ្ញុំនឹងដូចថាគេទុកចិត្តយើងណាស់គេអោយខ្ញុំយកមួយកញ្ឆេលនឹងម៉ងទៅគេដាក់ជឹងជាន់ពីដើមណាស់អាជឹងកាស់នឹងហើយមួយកញ្ឆេលនឹង១០០គីឡូគេសួរខ្ញុំថាយកអត់ខ្ញុំថាបើយកលុយខ្ញុំមុនខ្ញុំគ្មានលុយទេព្រោះខ្ញុំរៀនពេលល្ងាចដល់ពេលគេលក់អោយមួយកញ្ឆេលនឹង៨០គីឡូចឹងខ្ញុំថាយកអាតូចទៅ៨០គីឡូមួយគីឡូ១៥រយខ្ញុំលក់បាន២ពាន់៨ខ្ញុំលក់បានទិញមាសពាក់។

កៈ
បាត!ចឹងអ្នកមីងជាចុងក្រោយតើអ្នកមីងមានអ្វីចង់ផ្តែផ្តៅទៅកូនចៅជំនាន់ក្រោយកុំអោយដើរតាមកំលងអ្នកមីងអីចឹងណាស់?

ខៈ
ខ្ញុំចង់ផ្តែផ្តៅកូនអោយកូនដើរផ្លូវល្អកុំដើរតាមផ្លូវអាក្រក់កុំសេគបមិត្តភក្តិដែលមិនល្អអោយខំប្រឹងប្រែងរៀនសូត្រពេលទំនេពីរៀនសូត្រជួយធ្វើកិច្ចការផ្ទះទៅហើយរាល់ថ្ងៃនឹងម៉ែវាទិញទូរស្សន៍អោយ១ខ្ញុំទិញអោយវាមួយអោយនៅមើនៅផ្ទះទៅកុំដើរលេងវាមិនល្អរាល់ថ្ងៃនឹងខ្ញុំយកចៅពីរយកមកចិញ្ចឹមព្រោះម៉ែឪវាលេងគ្នាហើយខ្ញុំចង់អោយចៅរៀនសូត្រអោយចេះដឹងអាមួយជួយធ្វើការទៅបានដោះស្រាយជីវភាពដូចថាជួយចិញ្ចឹមយាយវិញមកនៅពេលដែលយាយចាស់ទៅពីក្មេងយាយចិញ្ចឹមចៅដល់ពេលយាយចាស់ទៅចៅចិញ្ចឹមយាយវិញទៅដល់ហើយបើមិនចីញ្ចឹមក៏មិនដឹងធ្វើមិចដែលយាយទៅវត្តក៏បានដែល។

កៈ
បាទ!ចឹងអ្នកមីងបើនិយាយពីការជៀសវាងតើអ្នកមីងចង់និយាយអោយកូនចៅចៀសវាងអ្វីខ្លះដែលអ្នកមីងដូចជាចៀសវាងពីគ្រឿងញៀញអីចឹងណាស់អ្នកមីង?

ខ៖ ចា៎!ខ្ញុំសូមអោយចៀសវាងពីគ្រឿងញៀនល្បែងស៊ីសងហាមផ្តាត់។

ក៖ បាទ!ហើយនឹងបងធំបងតូច?

ខ៖
នឹងបងធំបងតូចរាល់ថ្ងៃនឹងលេងបើថាគ្នាច្រើហៅចៅមកឡើងផ្ទះយាយទិញនំអោយរួតឡើងផ្ទះខ្ញុំមិនអោយលេងជុំគ្នាច្រើនទេជូនការអាធំវៃអាតូចអាតូចវៃអាធំទៅវាធ្វើអោយឈ្លួសគ្នាទៅស្រុកនឹងមិនថាស្រុកណាទេក្មេងៗវាតែតាចឹងហើយដូចថាអាធំវាវៃអាតូចចឹងយើងចេះតែហាមវាទៅដល់ពេលបើកូនយើងទៅវៃគេក៏ខ្ញុំថាអោយដែលខ្ញុំមិនកាន់ជើងអ្នកណាទេក្មេងវាឈ្លួសគ្នាតាមួយថ្ងៃវាត្រូវគ្នាវិញហើយចឹងបានថាកុំអោយវាលេងបើវាខូតវាខ្លាំងយើងដើរចេញទៅកុំទៅតវាជាមួយវាចឹងបានខ្ញុំថាបើឃើញបួកអាខូតៗមកខ្ញុំមិនអោយចៅខ្ញុំលេងជាមួយវាទេចឹងបានខ្ញុំចង់ផ្តៅផ្ញើទៅកូនចៅបើនៅណាជុំគ្នាច្រើនកុំទៅអោយសោះចៅខ្ញុំពិបាកព្រោះឪវានឹងជក់គ្រឿងញៀនជាប់គុកដល់ឥឡូវនឹងណាស់ខ្ញុំមិនដឹងថាវាដើរទៅណាមកណាអីខ្ញុំមិនដឹងទេអ្នកជិតខាងខ្លះគេយល់ណាស់តាឈូមនោះព្រឹកឡើងខ្ញុំពិបាកចិត្តពេកខ្ញុំអង្គុយចឹងណាស់ដល់ហើយតាឈូមនឹងគាត់ដើរមកគាត់ធ្លាប់ធ្វើសំណងជាមួយប្តីខ្ញុំណាស់ម៉ៅការសំណងដល់ពេលគាត់ឈប់រកជ្រូកទៅរកជ្រូកតាទឹកឡើងទេទៅវៀតណាមនឹងដល់ពេលអត់ទឹកឡើងទេគាត់ដើរម៉ៅការសំណងជាមួយគ្នាតាឈូមនឹងគាត់ថាម៉ែអាមីអើយអង្គុយគិតអីការនឹងកូនវានៅឈ្លួសគ្នាពីល្ងាចណាស់វាឈ្លួសគ្នាដោយសាគេវាឈ្លួសគ្នាទៅវិញទៅមកណាស់ដល់ហើយខ្ញុំថាពិបាកចិត្តណាស់ខ្ញុំដើរខ្ញុំចង់តែពាក់ម៉ាស់កុំអោយគេឃើញមុខរាល់ថ្ងៃនេះខ្ញុំខ្មាស់គេណាស់ដោយសារកូនតែចំពោះខ្ញុំមិនដែលធ្វើអោយពីណាគេស្អមខ្ពើមខ្ញុំទេខ្ញុំសន្សំតាក្តីសុខទេរាល់ថ្ងៃនេះខ្ញុំរកលុយបានប៉ុន្មនាខ្ញុំទុកហូបពិននឹងខ្ញុំមិនចង់បានរបស់អ្នកណាទេគេអាប់លុយអោយខ្ញុំលើសក៏ខ្ញុំមិនយកដែលថ្ងៃមុនខ្ញុំមានលុយ៥ពាន់ខ្ញុំទៅទិញអាណ្ដូង៥រយគេអោយខ្ញុំ២គេអាប់អោយខ្ញុំ៩ពាន់ដល់ហើយខ្ញុំនិយាយថាអញ្ចេកអ្នកលក់អើយលុយខ្ញុំក្រដាស់៥ពាន់ទេរួចចំណោញប៉ុន្មានអាប់អោយខ្ញុំលើសដល់៥ពាន់ហើយយកទៅវិញទៅហើយខ្ញុំទិញអាណ្ដូងគេតា៥រយទេខ្ញុំដក់មកតា៤ពាន់អាណ្ដូងនឹងវាស្អុយខ្ញុំក៏ទៅយកលុយមកវិញដល់ទៅខ្ញុំជិតទៅស្អុយមួយខ្ញុំថាអ្នកលក់អាណ្ដូងនឹងស្អុយមួយហើយលុយដែលលើស៥ពាន់នឹងអាប់អោយខ្ញុំតា៤ពាន់ហើយខ្វាស់ខ្ញុំ៥រយអោយខ្ញុំវិញមកគេក៏អោយខ្ញុំផ្លាមខ្ញុំថាខ្ញុំមិនចង់បានទេគាត់លក់ចំណោញបានតិចទេហើយគាត់លក់ក៏ធូរដែលអាណ្ដូងនឹងណាស់។

ក៖
បាទ!ចឹងជាចុងក្រោយខ្ញុំសូមអរគុណអ្នកមីងដែលអ្នកមីងអោយខ្ញុំធ្វើការសម្ភាសន៍អំពីជីវប្រវត្តរបស់អ្នកមីងហើយខ្ញុំសូមអរគុណអ្នកមីងមានសុខភាពល្អហើយនឹងសូមអោយកូនចៅរបស់អ្នកមីងមានសុខភាពល្អរកស៊ីមានបាន?

ខ៖
ចាំ!រាល់ថ្ងៃនឹងយាយខំឆ្លាតថាមីងអោយ១៥០អីចឹងឆ្លាតទៅទិញកង់អោយចៅ៦៥រៀលចិះអាកង់តូចនឹងឱវាទិញអោយនឹងជិះអត់កើតដូចថាកង់នឹងវាតូចណាស់វាទិញតាំងពីតូចដល់ហើយវាធំទៅវាជិះអត់កើតឆ្លាតទៅទិញទៅដល់

អូស្បីគេយកសាហុយ១០រៀលអស់ប៉ុន្មានអស់ទៅអោយតាបានកង់អោយចៅជិះខ្ញុំសូមផ្តាំទៅប្អូននៅខាងមុខថាពេលក្មេងៗចេញពីរៀននឹងសូមអោយជួយមើក្មេងៗផងរួតហើយគេនិយាយថាមិនអីទេមីងគេមើណាស់ដល់ហើយខ្ញុំថាអរគុណច្រើណាស់ក្មួយអើយព្រោះផ្លូវគេទុបតែធ្វើចឹងណាស់អាត្រាស់គេកែវណាស់ខ្ញុំភ័យណាស់ថ្ងៃមុននឹងខ្ញុំចេះតែដើបទាន់វាចឹងណាស់ដូចថាដើបវាមិនរួតចឹងណាស់ដូចថាឈឺក្បាលវើលមុខចឹងណាស់ថ្ងៃណាអត់ឈឺចឹងខ្ញុំរត់ទៅមើចៅទៅនាំចៅឆ្លងថ្នររួតហើយខ្ញុំទៅផ្តៅផ្ញើគេទៅក៏លែងភ័យហើយ។

ក៖
បាទ!ចឹងខ្ញុំសូមអរគុណអ្នកមីងច្រើនសូមអោយកូនចៅអ្នកមីងទាំងអស់គ្នារកស៊ីមានបានជួបតែសំណាងល្អសុខភាពល្អណាស់អ្នកមីងបាទចឹងខ្ញុំសូមជំរាបលាអ្នកមីងម្តងទៀតផងដែលអ្នកមីង។